# មុខវិជ្ជា៖
# គីមីសរីរាង្គ

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជាគីមីសរីរាង្គបរិយាយអំពីទម្រង់ រូបមន្តទូទៅ ទម្រង់ឡឺវីស ធរណីមាត្រម៉ូលេគុល ស្តេរ៉េអូគីមី ការហៅឈ្មោះ លក្ខណៈរូប លក្ខណៈគីមី ទង្វើ ប្រភពនិងបម្រើបម្រាស់របស់ក្រុមសមាសធាតុសរីរាង្គរួមមាន អាល់កាន អាល់សែន អាល់ស៊ីន អ៊ីដ្រូកាបួប្រហើរ អាល់កុល អេទែ អាល់ដេអ៊ីត សេតូន អាស៊ីតកាបុកស៊ីលិច អេស្ទែ ខ្លាញ់ ប្រេង និង សមាសធាតុប្រហើរ។

## លទ្ធផលសិក្សារំពឹងទុក

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

**លទ្ធផលរំពឹងទុកទី១** វិជ្ជាសម្បទា៖ចប់មេរៀននេះគរុនិស្សិតអាច

CLO1. រៀបរាប់ពីមូលដ្ឋានគ្រឹះនៃពាក្យបច្ចេកទេស និងបញ្ញតក្នុងគីមីសរីរាង្គ។

CLO2. ពណ៌នាលក្ខណៈរូប លក្ខណៈគីមី ទង្វើ ប្រភព និងបម្រើបម្រាស់របស់ក្រុមសមាសធាតុ សរីរាង្គ។

CLO3. ពណ៌នាពីគោលការណ៍គ្រឹះនៃគីមីសរីរាង្គ។

CLO4. រៀបរាប់ពីសុវត្ថិភាពក្នុងទីពិសោធ និងដំណើរការពិសោធ។

**លទ្ធផលរំពឹងទុកទី១** បំណិនសម្បទា៖ចប់មេរៀននេះគរុនិស្សិតអាច

CLO5. គូរទម្រង់ និងហៅឈ្មោះសមាសធាតុសរីរាង្គត្រឹមត្រូវតាមប្រព័ន្ធងាយ និងប្រព័ន្ធ IUPAC

CLO6. កំណត់បាននូវទម្រង់ផលិតផលប្រតិកម្មរបស់ក្រុមសមាសធាតុសរីរាង្គ

CLO7. ជ្រើសរើសវិធីសាស្ត្រត្រឹមត្រូវក្នុងការសំយោគសមាសធាតុសរីរាង្គ

CLO8. កំណត់បាននូវបម្រើបម្រាស់របស់សមាសធាតុសរីរាង្គក្នុងជីវភាពរស់នៅប្រចាំថ្ងៃ

**លទ្ធផលរំពឹងទុកទី៣** ឥរិយាបថសម្បទា៖ចប់មេរៀននេះគរុនិស្សិតអាច

CLO9. ប្រកាន់ភ្ជាប់ការប្រើប្រាស់មូលដ្ឋានគ្រឹះនៃគីមីសរីរាង្គដើម្បីដោះស្រាយចំណោទបញ្ហាក្នុងSTEM ឆ្លើយតបទៅនឹងបំណិនសិក្សាក្នុងសតវត្សទី២១។

CLO10. មានទំនួលខុសត្រូវជាប្រចាំ ក្នុងការធ្វើការងារដោយឯករាជ្យ និងពិភាក្សាជាក្រុមដោយ យកលំនាំនៃការសិក្សាពេញមួយជីវិត។

**របាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖ តេស្ត Google Form

កិច្ចការទី ២៖ កិច្ចការឆ្លុះបញ្ចាំង

# អារម្ភកថា

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីវិក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃ ចន្ទ ១២កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## គណៈកម្មការ

### ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ម៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អង្គារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

### ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សុត្រ** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក ការមេអ៊ាន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់រឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាត** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត ខសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន ឥមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ូ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ីម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ឡៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

### ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អង្គារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ចៅ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សាអ៊ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

### ៤. ការរីកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ាអ៊ី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

២. លោក **ឌុន សំណាង** បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្ដោតលើប្រតិបត្តិជាក់ស្ដែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្តទំនាក់-ទំនង សេចក្ដីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសគីមីប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសគីមីកម្រិតបរិញ្ញាបត្រ**

- មុខវិជ្ជា គីមីរូប
- មុខវិជ្ជា គីមីសរីរាង្គ
- មុខវិជ្ជា គីមីវិភាគ
- មុខវិជ្ជា គីមីអសរីរាង្គ
- មុខវិជ្ជា ស្ថិតិវិភាគសម្រាប់អ្នកគីមី
- ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

- ❖ សន្និកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ❖ ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសគីមី

**(២) ចំណេះដឹងវិធីគរុកោលស្យ សាស្ត្របង្រៀន និងការអប់រំគីមីកម្រិតមធ្យមសិក្សា**

- ❖ វិធីសាស្ត្របង្រៀន
- ❖ វិធីសាស្ត្រវង្វាយតម្លៃ
- ❖ ការស្រាវជ្រាវប្រតិបត្តិ
- ❖ ប្រឹក្សាគរុកោសល្យ
- ❖ បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោលស្យ និងការអនុវត្តជាក់ស្តែង**

- ❖ អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ❖ ការអនុវត្តកម្មវិធីស្វ័យសិក្សាគីមី ពីទីថ្នាក់៧-ទី១២
- ❖ របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនគីមីប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនគីមី និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្ដាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

# កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្ដោតលើបណ្ដុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្ដែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្ដងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្ដែងកន្លងមក ។

| បណ្ដុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្ដែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្តុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | មុខវិជ្ជា គីមីរូប | ៣ |
| | មុខវិជ្ជា គីមីសរីរាង្គ | ៣ |
| | មុខវិជ្ជា គីមីវិភាគ | ៣ |
| | មុខវិជ្ជា គីមីអសរីរាង្គ | ៣ |
| | មុខវិជ្ជា ស្ថិតិវិភាគសម្រាប់អ្នកគីមី | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការឯកទេសគីមីសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ* | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

### ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើ

វិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹងវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

RUPPDOC

# ជំពូកទី១

# អ៊ីដ្រូកាបួ



RUPPDOC

## មេរៀនទី១

## អ៊ីដ្រូកាបួឆ្អែត៖ អាល់កាន

# វត្ថុបំណង

## ក្នុងមេរៀននេះយើងនឹងអាច៖

- សរសេរទម្រង់ និងការហៅឈ្មោះអាល់កាន
- រៀបរាប់លក្ខណៈរូប និងលក្ខណៈគីមីរបស់អាល់កាន
- រៀបរាប់អំពីប្រភេទ និងបម្រើបម្រាស់របស់អាល់កាន

3

# ១. សេចក្តីផ្តើម

## តើគីមីសរីរាង្គសិក្សាអំពីអ្វី?

- **គីមីសរីរាង្គ**គឺជាការសិក្សាលើសមាសធាតុកាបូន។
- ទោះបីជាកាបូនជាធាតុចំបងនៅក្នុងសមាសធាតុសរីរាង្គក៏ដោយ ក៏គេតែងតែសង្កេតឃើញធាតុអ៊ីដ្រូសែន និងធាតុដទៃទៀតដូចជាអាសូត អុកស៊ីសែន ផូស្វ័រ ស្ពាន់ធ័រ ក្លរ និងធាតុដទៃទៀតក្នុងសមាសធាតុសរីរាង្គដែរ។
- សមាសធាតុជាច្រើននៅក្នុងធម្មជាតិដូចជា អាហារ សម្លៀកបំពាក់ (កប្បាស រោមសត្វ សូត្រ) ឥន្ធនៈ (ឧស្ម័នធម្មជាតិ, សាំង, ប្រេង...) ក៏ជាសមាសធាតុសរីរាង្គដែរ។ ប៉ុន្តែមិនមែនមានន័យថា សមាសធាតុ សរីរាង្គមានតែនៅក្នុងធម្មជាតិទេ។
- អ្នកគីមីបានសិសក្សាអំពីការសំយោគសមាសធាតុសរីរាង្គជាច្រើនលានម៉ូលេគុលដែលមិនមាននៅក្នុងធម្មជាតិដូចជា ក្រណាត់សំយោគ ប្លាស្ទិក កៅស៊ូសំយោគ ឱសថ ហើយសូម្បី តែហ្វីលរូបថត និងការ។

# ១. សេចក្ដីផ្ដើម

## ១.១ ទម្រង់នៃអ៊ីដ្រូកាបួមួយចំនួន




អេតាន




អេទីឡែន




អាសេទីឡែន



បង់សែន

- អ៊ីដ្រូកាបួ ជាឈ្មោះរួមនៃអង្គធាតុសរីរាង្គដែលមានធាតុបង្កពីរគឺ កាបូន និងអ៊ីដ្រូសែន។
- ឧទាហរណ៍៖ មេតាន($CH_4$) និងអេតាន($C_2H_6$) ជាអ៊ីដ្រូកាបួ ដែលវាជាពពួកក្រុមអាល់កាន។ រូបមន្តទូទៅរបស់អ៊ីដ្រូកាបួគឺ CxHy ដែលមានម៉ាសម៉ូល M=12x + y ។



១. សេចក្ដីផ្ដើម

## ១.២ ឈ្មោះបុព្វបទ របស់កាបូនតាមអក្សរឡាតាំង

- មុននឹងយើងសិក្សាទៅលើអ៊ីដ្រូកាបួឱ្យកាន់តែស៊ីជម្រៅនោះ ដំបូងយើងត្រូវស្គាល់ឈ្មោះបុព្វបទរបស់កាបូនជាមុនសិន។

| ចំនួនកាបូន | បុព្វបទអក្សរឡាតាំង | បុព្វបទអក្សរខ្មែរ | ចំនួនកាបូន | បុព្វបទអក្សរឡាតាំង | បុព្វបទអក្សរខ្មែរ |
|---|---|---|---|---|---|
| 1 | Meth | មេ | 6 | Hex | អិច |
| 2 | Eth | អេ | 7 | Hept | អិប |
| 3 | Prop | ប្រូ | 8 | Oct | អុក |
| 4 | But | ប៊ុយ | 9 | Non | ណូ |
| 5 | Pent | ប៉ង់ | 10 | Dec | ដេ |

# ១. សេចក្តីផ្តើម

## ១.៤ ទម្រង់ម៉ូលេគុល របស់ប្រភេទនៃអ៊ីដ្រូកាបួនីមួយៗ

- អាល់កាន: មានសម្ព័ន្ធរវាកាបូន និងកាបូន(C–C) ជាសម្ព័ន្ធមួយជាន់ទាំងអស់។ នៅក្នុងការ ហៅឈ្មោះគឺត្រូវបានបញ្ចប់ដោយពាក្យ អាន (ane)។
- អាល់សែន: មានសម្ព័ន្ធរវាកាបូន និងកាបូន(C=C) ជាសម្ព័ន្ធពីរជាន់ចំនួនមួយ ក្រៅពីនោះ សុទ្ធតែសម្ព័ន្ធមួយជាន់។ ក្នុងការហៅឈ្មោះគឺត្រូវបានបញ្ចប់ដោយពាក្យ អែន (ene)។
- អាល់ស៊ីន: មានសម្ព័ន្ធរវាកាបូន និងកាបូន(C≡C) ជាសម្ព័ន្ធបីជាន់ចំនួនមួយក្រៅពីនោះ សុទ្ធតែសម្ព័ន្ធមួយជាន់។នៅក្នុងការហៅឈ្មោះគឺត្រូវបានបញ្ចប់ដោយពាក្យ អ៊ីន (yne)។
- សមាសធាតុអ៊ីដ្រូកាបួប្រហើរ: មានផ្ទុកខ្សែវង់ពិសេស ដូចជាវង់បង់សែន ដែលមិនមានបច្ច័មបទច្បាស់លាស់ទេ គឺវាអាស្រ័យទៅតាមអម្បូរនៃសមាសធាតុប្រហើរនោះ។



# ២. នាមវលី

- **អាល់កាន**ជាអ៊ីដ្រូកាបួដែលមានទម្រង់ម៉ូលេគុលរបស់វាគឺសម្ព័ន្ធរវាងកាបូន និងកាបូនសុទ្ធ តែជាសម្ព័ន្ធមួយជាន់ទាំងអស់។ អាល់កានមានរូបមន្តទូទៅ $C_nH_{2n+2}$ ដែល $n \geq 1$

| ឈ្មោះ | ចំនួនកាបូន | រូបមន្តស្ទើរលាត | ឈ្មោះ | ចំនួនកាបូន | រូបមន្តស្ទើរលាត |
|---|---|---|---|---|---|
| មេតាន | 1 | $CH_4$ | អង់ដេកាន | 11 | $CH_3(CH_2)_9CH_3$ |
| អេតាន | 2 | $CH_3CH_3$ | ដូដេកាន | 12 | $CH_3(CH_2)_{10}CH_3$ |
| ប្រូប៉ាន | 3 | $CH_3CH_2CH_3$ | ទ្រីដេកាន | 13 | $CH_3(CH_2)_{11}CH_3$ |
| ប៊ុយតាន | 4 | $CH_3(CH_2)_2CH_3$ | តេត្រាដេកាន | 14 | $CH_3(CH_2)_{12}CH_3$ |
| ប៉ង់តាន | 5 | $CH_3(CH_2)_3CH_3$ | ប៉ង់តាដេកាន | 15 | $CH_3(CH_2)_{13}CH_3$ |
| អិចសាន | 6 | $CH_3(CH_2)_4CH_3$ | អិចសាដេកាន | 16 | $CH_3(CH_2)_{14}CH_3$ |
| អិបតាន | 7 | $CH_3(CH_2)_5CH_3$ | អិបតាដេកាន | 17 | $CH_3(CH_2)_{15}CH_3$ |
| អុកតាន | 8 | $CH_3(CH_2)_6CH_3$ | អុកតាដេកាន | 18 | $CH_3(CH_2)_{16}CH_3$ |
| ណូណាន | 9 | $CH_3(CH_2)_7CH_3$ | ណូណាដេកាន | 19 | $CH_3(CH_2)_{17}CH_3$ |
| ដេកាន | 10 | $CH_3(CH_2)_8CH_3$ | អេកូសាន | 20 | $CH_3(CH_2)_{18}CH_3$ |

# ២. នាមវលី

RUPPDOC

## ២.១ អាល់កានខ្សែធោល

- អាល់កានខ្សែត្រង់ដែលមានចំនួនកាបូនចាប់ពី៤ ឡើងទៅ:

n –បុព្វបទ + អាន

- ឧទាហរណ៍៖

$CH_3–CH_2–CH_2–CH_3$ n–ប៊ុយតាន

$CH_3–CH_2–CH_2–CH_2–CH_3$ n–ប៉ង់តាន

$CH_3–CH_2–CH_2–CH_2–CH_2–CH_3$ n–អិចសាន



# ១. នាមវលី

RUPPDOC

## ១.២ នាមវលីបណ្តុំអាល់គីល

- ការហៅឈ្មោះខ្នែងនៃបណ្តុំអាល់គីលគឺធ្វើទៅតាមចំនួនកាបូនដូចអាល់កានដែរ តែត្រូវប្តូរពីបច្ចឹមបទ អាន ទៅ អ៊ីល។

| ទម្រង់ស្ទើរលាត | ឈ្មោះ | ទម្រង់ស្ទើរលាត | ឈ្មោះ |
|---|---|---|---|
| $CH_3–$ | មេទីល | $CH_3-CH_2-CH_2-CH_2–$ | n–ប៊ុយទីល |
| $CH_3–CH_2–$ | អេទីល | $CH_3-CH_2-CH(CH_3)–$ | សិកប៊ុយទីល |
| $CH_3–CH_2–CH_2–$ | n–ប្រូពីល | $CH_3-CH(CH_3)-CH_2–$ | អ៊ីសូប៊ុយទីល |
| $CH_3-CH(CH_3)–$ | អ៊ីសូប្រូពីល | $CH_3-C(CH_3)_2–$ | ទែត្យូប៊ុយទីល |

# ២. នាមវលី

## ២.៣ អាល់កានខ្សែខ្វែង

- ដើម្បីហៅឈ្មោះអាល់កានដែលមានខ្សែកាបូនមានខ្វែងត្រូវតាមវិធីខាងក្រោម:




❖នៅពេលមានខ្វែងដូចគ្នាចំនួន ២ ៣ ៤ ត្រូវហៅពាក្យ ឌី ទ្រី តេត្រា នៅខាងមុខ។

- ឧទាហរណ៍៖



2–មេទីលប៉ង់តាន



2,4–ឌីមេទីលអិចសាន



# ២. នាមវលី

## ២.៣ អាល់កានខ្សែខ្វែង

- កាលណារ៉ាឌីកាល់មេទីល$CH_3$ ភ្ជាប់ទៅលើកាបូនលេខ2នៃខ្សែមេ ឈ្មោះដើមនៃអាល់កាន គេបន្ថែមពាក្យ អ៊ីសូនៅមុខឈ្មោះអាល់កាន។
- ឧទាហរណ៍៖



អ៊ីសូប្រូប៉ាន



អ៊ីសូប៊ុយតាន



អ៊ីសូប៉ង់តាន

# ២. នាមវលី

## ២.៣ អាល់កានខ្សែបែកខ្នែង

- អនុវត្តន៍៖ ចូរហៅឈ្មោះអាល់កានខាងក្រោម៖





- អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើរលាតរបស់សមាសធាតុខាងក្រោម៖

ក.n–ប៉ង់តាន

ខ.3–អេទីល–2–មេទីលអិចសាន



# ២. នាមវលី

## ២.៤ ទម្រង់ម៉ូលេគុលខាយៗ

### ក. មេតាន

$CH_4$

រូបមន្តស្ទើរលាត



រូបមន្តលាត



គម្រូឃ្លាត ឬ គម្រូបាល់-ចង្កឹះ

### ខ. អេតាន

$C_2H_6$

រូបមន្តស្ទើរលាត



រូបមន្តលាត



គម្រូឃ្លាត ឬ គម្រូបាល់-ចង្កឹះ

### គ. ប្រូប៉ាន

$C_3H_8$

រូបមន្តស្ទើរលាត



រូបមន្តលាត



គម្រូឃ្លាត ឬ គម្រូបាល់-ចង្កឹះ

RUPPDOC

# ៣. អ៊ីសូមែ

- អ៊ីសូមែជាសមាសធាតុទាំងឡាយណាដែលមានរូបមន្តម៉ូលេគុល(រូបមន្តដុល)ដូចគ្នា ប៉ុន្តែទម្រង់ ស្ទើរលាតខុសគ្នា។

- ឧទាហរណ៍ ១៖ $C_4H_{10}$ មានអ៊ីសូមែ៖

- ឧទាហរណ៍ ២៖ $C_6H_{12}$ មានអ៊ីសូមែ៖



RUPPDOC

# ៣. អ៊ីសូមែ

- អនុវត្តន៍៖ចូរគូររូបមន្តស្ទើរលាតនៃអ៊ីសូមែទាំងអស់របស់អាល់កាន $C_7H_{16}$ ៖

RUPPDOC

# ៤. លក្ខណៈរូប

- អាល់កានរាវមិនរលាយក្នុងទឹក និងស្រាលជាងទឹក តែវាអាចរលាយក្នុងធាតុរំលាយសរីរាង្គ។

- អាល់កានបួនតួដំបូងជាឧស្ម័ន ចាប់ពីតួទីប្រាំដល់តួទីដប់ប្រាំជាអង្គធាតុរាវ និងចាប់ពីតួទីដប់ប្រាំមួយ ទៅជាអង្គធាតុរឹង។



RUPPDOC

# ៤. លក្ខណៈរូប

| នាមវលី | រូបមន្តម៉ូលេគុល | សីតុណ្ហភាពរលាយ | សីតុណ្ហភាពរំពុះ | ភាពរូប |
|---|---|---|---|---|
| មេតាន | $CH_4$ | –182°C | –162°C | ឧស្ម័ន |
| អេតាន | $C_2H_6$ | –183 °C | –89 °C | ឧស្ម័ន |
| ប្រូប៉ាន | $C_3H_8$ | –187 °C | –42 °C | ឧស្ម័ន |
| ប៊ុយតាន | $C_4H_{10}$ | –138 °C | –0.5 °C | ឧស្ម័ន |
| ប៉ង់តាន | $C_5H_{12}$ | –130 °C | 36 °C | រាវ |
| អិចសាន | $C_6H_{14}$ | –95 °C | 69 °C | រាវ |

# ៤. លក្ខណៈរូប

| នាមវលី | រូបមន្តម៉ូលេគុល | សីតុណ្ហភាពរលាយ | សីតុណ្ហភាពរំពុះ | ភាពរូប |
|---|---|---|---|---|
| អិបតាន | $C_7H_{16}$ | –91 °C | 98 °C | រាវ |
| អុកតាន | $C_8H_{18}$ | –57 °C | 126 °C | រាវ |
| ណូណាន | $C_9H_{20}$ | –54 °C | 151 °C | រាវ |
| ដេកាន | $C_{10}H_{22}$ | –30 °C | 174 °C | រាវ |
| --- | --- | --- | --- | --- |
| អិចសាដេកាន | $C_{16}H_{34}$ | | | រឹង |



# ៥. ប្រតិកម្ម

## ៥.១ ប្រតិកម្មចំហេះ

- ប្រតិកម្មចំហេះ គឺជាប្រតិកម្មនៃល្បាយអាចឆេះបានជាមួយអុកស៊ីសែន។
- ចំហេះសព្វអាល់កានឱ្យផលជាទឹក កាបូនឌីអុកស៊ីត និងកម្ដៅ។
- បើបរិមាណអុកស៊ីសែនមិនគ្រប់គ្រាន់ ចំហេះអាល់កានឱ្យផលជា C CO $CO_2$ និង $H_2O$។

**សមីការតាងប្រតិកម្មចំហេះសព្វអាល់កាន:**

$$C_nH_{2n+2} + \frac{(3n+1)}{2} O_2 \rightarrow n\,CO_2 + (n+1)\,H_2O$$

អាល់កាន      កាបូនឌីអុកស៊ីត      ទឹក

- ឧទាហរណ៍៖
  - $C_4H_{10} + O_2 \rightarrow$
  - $C_8H_{18} + O_2 \rightarrow$

RUPPDOC

# ៥. ប្រតិកម្ម

## ៥.២ ប្រតិកម្មអាឡូសែនកម្ម

- ប្រតិកម្មអាឡូសែនកម្ម គឺជាប្រតិកម្មជំនួសអាតូមH របស់អ៊ីដ្រូកាបួណាមួយ ដោយអាតូមអាឡូសែន។

**សមីការតាងប្រតិកម្មអាឡូសែនកម្ម អាល់កាន**

$$C_nH_{2n+2} + X_2 \xrightarrow{h\nu} C_nH_{2n+1}X + HX$$

អាល់កាន អាឡូសែន អាល់គីលអាឡូសែនូ អ៊ីដ្រូសែនអាឡូសែនូ

- ឧទាហរណ៍៖
  - $C_2H_6 + Cl_2 \rightarrow$
  - $C_3H_8 + Br_2 \rightarrow$



RUPPDOC

# ៥. ប្រតិកម្ម

## ៥.២ ប្រតិកម្មអាឡូសែនកម្ម

- ក្រោមលក្ខខណ្ឌពន្លឺសាយនៃថ្ងៃ មេតានមានប្រតិកម្មជាមួយឧស្ម័នក្លរ ដោយអាតូម អ៊ីដ្រូសែនត្រូវបាន ជំនួសដោយ អាតូមក្លរ ប្រតិកម្មនេះប្រព្រឹត្តទៅរហូតដល់អស់អាតូមអ៊ីដ្រូសែនក្នុងម៉ូលេគុល:

$$CH_4 + Cl_2 \xrightarrow{h\nu} CH_3Cl + HCl$$

ក្លរ៉ូមេតាន

$$CH_3Cl + Cl_2 \xrightarrow{h\nu} CH_2Cl_2 + HCl$$

ឌីក្លរ៉ូមេតាន

$$CH_2Cl_2 + Cl_2 \xrightarrow{h\nu} CHCl_3 + HCl$$

ទ្រីក្លរ៉ូមេតាន ឬ ក្លរ៉ូផម

$$CHCl_3 + Cl_2 \xrightarrow{h\nu} CCl_4 + HCl$$

តេត្រាក្លរ៉ូមេតាន

RUPPDOC

# ៥. ប្រតិកម្ម

## ៥.៣ ប្រតិកម្មក្រាក់គិញ

- ក្រាគិញជាលំនាំបំបែកអ៊ីដ្រូកាបួឆ្អែតដោយប្រើកម្តៅ ក្នុងមជ្ឈដ្ឋានគ្មានខ្យល់។

**សមីការតាងប្រតិកម្មក្រាគិញ អាល់កាន**

$$C_nH_{2n+2} \xrightarrow{t^\circ} C_xH_{2x} + C_yH_{2y+2}$$

អាល់កាន

- ឧទាហរណ៍៖

$$C_4H_{10} \xrightarrow{t^\circ} CH_4 + C_3H_6$$

$$C_4H_{10} \xrightarrow{t^\circ} C_2H_4 + C_2H_6$$

$$C_4H_{10} \xrightarrow{t^\circ} H_2 + C_4H_8$$



RUPPDOC

# ៥. ប្រតិកម្ម

## ៥.៤ ប្រតិកម្មនីត្រកម្ម

- នីត្រកម្ម គឺជាប្រតិកម្មជំនួសអាតូម H មួយ ឬច្រើនរបស់អ៊ីដ្រូកាបួដោយបង្គុំ $-NO_2$ របស់ $HNO_3$ ដែលមាន $H_2SO_4$ ខាប់ជាកាតាលីករ។

**សមីការតាងប្រតិកម្មនីត្រកម្ម អាល់កាន**

$$C_nH_{2n+2} + HO{-}NO_2 \xrightarrow{H_2SO_4} C_nH_{2n+1}{-}NO_2 + H_2O$$

អាល់កាន　អាស៊ីតនីទ្រិច　នីត្រូអាល់កាន　ទឹក

- ឧទាហរណ៍៖

➢ $CH_4 + HNO_3 \rightarrow$

➢ $C_3H_8 + HNO_3 \rightarrow$

# ៦. ទង្វើ

## ៦.១ អ៊ីដ្រូសែនកម្មនៃអាល់សែន

- ប្រតិកម្មអ៊ីដ្រូសែនកម្មអាល់សែន ជាប្រតិកម្មបូកអ៊ីដ្រូសែនទៅលើអាល់សែន។

**សមីការតាងប្រតិកម្មអ៊ីដ្រូសែនកម្មអាល់សែន**

$$C_nH_{2n} + H_2 \xrightarrow{Ni/t^{\circ}} C_nH_{2n+2}$$

- ឧទាហរណ៍៖ ដោយប្រើកាតាលីកររលោហៈនីកែល និងដុតកម្ដៅ៖

  - $C_2H_4 + H_2 \rightarrow$
  - $C_3H_6 + H_2 \rightarrow$
  - $CH_2{=}CH{-}CH_2CH_3 + H_2 \rightarrow$



# ៦. ទង្វើ

## ៦.២ អ៊ីដ្រូសែនកម្មអាល់ស៊ីន

- ប្រតិកម្មអ៊ីដ្រូសែនកម្មអាល់ស៊ីន ជាប្រតិកម្មបូកអ៊ីដ្រូសែនទៅលើអាល់ស៊ីន។

**សមីការតាងប្រតិកម្មអ៊ីដ្រូសែនកម្មអាល់ស៊ីន**

$$C_nH_{2n-2} + 2H_2 \xrightarrow{Ni/t^{\circ}} C_nH_{2n+2}$$

អាល់ស៊ីន → អាល់កាន

- ឧទាហរណ៍៖ ដោយប្រើកាតាលីកររលោហៈនីកែល និងដុតកម្ដៅ៖

  - $C_2H_2 + H_2 \rightarrow$
  - $C_3H_4 + H_2 \rightarrow$
  - $CH_2{\equiv}CH{-}CH_2CH_3 + H_2 \rightarrow$

# ៦. ទង្វើ

## ៦.៣ ពីសូដ្យូមកាបុកស៊ីឡាត $C_nH_{2n+1}COONa$

- សូដ្យូមកាបុកស៊ីឡាត មានអំពើជាមួយស៊ូត ច្របល់កំបោររស់លើស គេទទួលបានអាល់កាន។

សមីការតាងប្រតិកម្មសូដ្យូមកាបុកស៊ីឡាត មានអំពើជាមួយស៊ូត ច្របល់កំបោររស់

$$C_nH_{2n+1}COONa + NaOH \xrightarrow{CaO/t^{\uparrow}} C_nH_{2n+2} + Na_2CO_3$$

សូដ្យូមកាបុកស៊ីឡាត អាល់កាន

- ឧទាហរណ៍៖ ដោយច្របល់សារធាតុខាងក្រោមជាមួយកំបោររស់ និងដុតកម្ដៅ៖

  - $CH_3COONa + NaOH \rightarrow$
  - $C_2H_5COONa + NaOH \rightarrow$
  - $C_3H_7COONa + NaOH \rightarrow$



# ៧. បម្រើបម្រាស់

- គេប្រើអាល់កានជាប្រភពថាមពល ដូចជាចំហេះក្នុងម៉ាស៊ីន និងចង្ក្រានហ្គាស។ ជាវត្ថុធាតុដើម សម្រាប់ឧស្សាហកម្មគីមីដើម្បីសំយោគគ្រឿងប្រើប្រាស់ដូចជា សសៃសំយោគ ប្លាស្ទិច ថ្នាំពេទ្យ...។

- ក្រៅពីប្រើជាឥន្ធនៈ គេប្រើមេតានដើម្បីទង្វើ៖
  - ទឹកខ្មៅនៅរោងពុម្ព
  - មេទីលក្លរួ ($CH_3Cl$) ប្រើជាមេត្រជាក់
  - ឌីក្លរ៉ូមេតាន ($CH_2Cl_2$) ប្រើជាធាតុរំលាយសរីរាង្គ
  - ក្លរ៉ូផម ($CHCl_3$) ប្រើជាថ្នាំសន្លប់ ឬស្ពឹកសម្រាប់វះកាត់
  - កាបូនតេត្រាក្លរួ ($CCl_4$) ប្រើជាធាតុរំលាយសរីរាង្គ

RUPPDOC

# លំហាត់គំរូទី ១

អាល់កានមួយមានម៉ាសម៉ូល 58g/mol។

ក) ចូរកំណត់រូបមន្តម៉ូលេគុលនៃអាល់កាន។

ខ)ចូរសរសេររូបមន្តស្ទើរលាតនៃអ៊ីសូមែព្រមទាំងហៅឈ្មោះអ៊ីសូមែនិមួយៗ។ (គេឱ្យ C =12g/mol, H=1g/mol)



RUPPDOC

# ដំណោះស្រាយ

RUPPDOC

## លំហាត់គំរូទី២

អ៊ីដ្រូកាបួឆ្អែតមួយមានភាគរយជាម៉ាសនៃអាតូមC=83.72%។ ចូរកំណត់រូបមន្តម៉ូលេគុលនៃ អ៊ីដ្រូកាបួឆ្អែត។



RUPPDOC

## ដំណោះស្រាយ

អ៊ីដ្រូកាបួឆ្អែតមួយមានភាគរយជាម៉ាសនៃអាតូមC=83.72% ។ ចូរកំណត់រូបមន្តម៉ូលេគុលនៃអ៊ីដ្រូកាបួឆ្អែត។

# លំហាត់គំរូទី៣

ចំហេះសព្វ 29g នៃអ៊ីដ្រូកាបួឆ្អែតមួយ គេទទួលបានទឹក 45g ។

ក.កំណត់រូបមន្តម៉ូលេគុលនៃអ៊ីដ្រូកាបួនេះ ។

ខ.គណនាមាឌខ្យល់ដែលត្រូវប្រើគេដឹងថាខ្យល់មានអុកស៊ីសែន1/5គិតជាមាឌ។

គេឱ្យ Vm=22.4L/mol



# ដំណោះស្រាយ

RUPPDOC

## ដំណោះស្រាយ



RUPPDOC

# មេរៀនទី២

# អ៊ីដ្រូកាបួមិនឆ្អែត

# អាល់សែន និងអាល់ស៊ីន

RUPPDOC

# វត្ថុបំណង

## ក្នុងមេរៀននេះយើងនឹងអាច៖

- គូរទម្រង់ និងហៅឈ្មោះអាល់សែន និងអាល់ស៊ីន
- រៀបរាប់លក្ខណៈរូប និងលក្ខណៈគីមីរបស់អាល់សែន និងអាល់ស៊ីន
- រៀបរាប់អំពីទង្វើ និងបម្រើបម្រាស់របស់អាល់សែន និងអាល់ស៊ីន



RUPPDOC

# ១. អាល់សែន

## ១.១ សេចក្ដីផ្ដើម

- អាល់សែនជាអ៊ីដ្រូកាបួខ្សែបើកដែលមានសម្ព័ន្ធពីរជាន់មួយក្នុងម៉ូលេគុល។
- អាល់សែន មានរូបមន្តទូទៅ $C_nH_{2n}$ ដែល $n \geq 2$ ។

| n | រូបមន្តទូទៅ $C_nH_{2n}$ | ឈ្មោះ |
|---|---|---|
| 2 | $C_2H_4$ | អេតែន |
| 3 | $C_3H_6$ | ប្រូប៉ែន |
| 4 | $C_4H_8$ | ប៊ុយតែន |
| 5 | $C_5H_{10}$ | ប៉ង់តែន |
| 6 | $C_6H_{12}$ | អិចសែន |
| 7 | $C_7H_{14}$ | អិបតែន |
| 8 | $C_8H_{16}$ | អុកតែន |
| 9 | $C_9H_{18}$ | ណូណែន |
| 10 | $C_{10}H_{20}$ | ដេកែន |

RUPPDOC

# ១. អាល់សែន

## ១.២ នាមវលី

### ក. អាល់សែនដែលមានខ្សែកាបូនត្រង់

- ការហៅឈ្មោះអាល់សែនងាយ៖

$CH_2{=}CH_2$ អេទីឡែន ឬ អេតែន $CH_2{=}CH{-}CH_3$ ប្រូប៉ែន

- ការហៅឈ្មោះអាល់សែនខ្សែកាបូនត្រង់៖
  1. ការបង់លេខ ចាប់ពី n ≥ 4 យើងត្រូវបង់លេខដោយលៃយ៉ាងណាឱ្យលេខកាបូនដែលមានសម្ព័ន្ធពីរជាន់មានលេខតូចបំផុតដែលអាចធ្វើទៅបាន។
  2. ឈ្មោះ ត្រូវហៅ [បុព្វបទខ្សែកាបូន + ទីតាំង= + បច្ច័មបទ"អែន"]។

- ឧទាហរណ៍៖

$$\overset{1}{CH_2}=\overset{2}{CH}-\overset{3}{CH_2}-\overset{4}{CH_3}$$

ប៊ុយ-1-អែន

$$\overset{1}{CH_3}-\overset{2}{CH}=\overset{3}{CH}-\overset{4}{CH_3}$$

ប៊ុយ-2-អែន



RUPPDOC

# ១. អាល់សែន

## ១.២ នាមវលី

### ខ.អាល់សែនដែលមានខ្នែង

- ដើម្បីហៅឈ្មោះអាល់សែនដែលមានខ្នែងត្រូវ:

**ជ្រើសរើសខ្សែមេ**
- មានសម្ព័ន្ធពីរជាន់
- ខ្សែកាបូនវែងជាងគេ
- ខ្នែងច្រើនជាងគេ

**បង់លេខ**
- សម្ព័ន្ធ២ជាន់មានលេខតូចបំផុត
- ខ្នែងមានលេខតូចបំផុត

**ហៅឈ្មោះ**
[ទីតាំងខ្នែង+ឈ្មោះខ្នែង + បុព្វបទខ្សែមេ+ ទីតាំង(=) + អែន

- ឧទាហរណ៍៖

$$\overset{1}{CH_2}=\overset{2}{CH}-\overset{3}{CH}(CH_3)-\overset{4}{CH_3}$$

3-មេទីលប៊ុយ-1-អែន

$$\overset{1}{CH_3}-\overset{2}{CH_2}-\overset{3}{CH}=\overset{4}{CH}-\overset{5}{CH}(CH_3)-\overset{6}{CH}(\overset{7}{CH_2}-\overset{8}{CH_3})-CH_3$$

5,6-ឌីមេទីលអុក-3-អែន

# ១. អាល់សែន

## ១.២ នាមវលី

- អនុវត្តន៍៖ចូរហៅឈ្មោះសមាសធាតុខាងក្រោម៖

  ក. $CH_3–CH_2–CH=CH–CH_2–CH_3$

  ខ. $CH_3–CH=CH–CH(CH_3)–CH_2–CH_3$

- អនុវត្តន៍៖ចូរសរសេររូបមន្តស្ទើរលាតរបស់សមាសធាតុខាងក្រោម៖

  A. 4–អេទីល–2–មេទីលអិច–2–អែន

  B. 2–ក្លរ៉ូ–4–មេទីលប៉ង់–2–អែន

  C. 4–ប្រូម៉ូ–2–មេទីល–2–នីត្រូអិច–3–អែន



# ១. អាល់សែន

## ១.៣ ទម្រង់ម៉ូលេគុលអាល់សែនងាយ

### អេតែន ឬអេទីឡែន

$CH_2=CH_2$

រូបមន្តស្ទើរលាត



រូបមន្តលាត



គម្រូឃ្លាត ឬគម្រូបាល់-ចង្កឹះ



រូបមន្តបន្ទាត់

### ប្រូប៉ែន

$CH_2=CH-CH_3$

រូបមន្តស្ទើរលាត



រូបមន្តលាត



គម្រូឃ្លាត ឬគម្រូបាល់-ចង្កឹះ



រូបមន្តបន្ទាត់

# ១. អាល់សែន

## ១.៤ អ៊ីសូមែរទីតាំង និងអ៊ីសូមែរខ្សែកាបូន

- ដើម្បីសរសេររូបមន្តស្ទើរលាតនៃអាល់សែន គេត្រូវយកអ៊ីសូមែរនៃអាល់កានដែលត្រូវនឹងវា មកបន្ថែមសម្ព័ន្ធពីរជាន់ចំនួនមួយ។
- ឧទាហរណ៍៖ សរសេររូបមន្តស្ទើរលាត ហៅឈ្មោះអ៊ីសូមែទាំងអស់របស់ និងបញ្ជាក់ពីទំនាក់ទំនងអ៊ីសូមែរបស់ពួកវា៖

  a. $C_4H_8$

8

# ១. អាល់សែន

## ១.៤ អ៊ីសូមែរទីតាំង និងអ៊ីសូមែរខ្សែកាបូន

- អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើរលាតនៃអ៊ីសូមែរទាំងអស់របស់អាល់សែន $C_5H_{10}$ និងបញ្ជាក់ពីទំនាក់ទំនងអ៊ីសូមែរទីតាំង និងខ្សែកាបូនរបស់ពួកវា។

9

RUPPDOC

# ១. អាល់សែន

## ១.៥ លក្ខណៈរូប

- អាល់សែនបីតួដំបូង $C_2H_4$ $C_3H_6$ និង$C_4H_8$ ជាឧស្ម័នគ្មានពណ៌ ចាប់ពី $C_5H_{10}$ ទៅជាអង្គធាតុរាវ
- អាល់សែនមិនរលាយក្នុងទឹក តែរលាយក្នុងអង្គធាតុរំលាយសរីរាង្គ។

| ឈ្មោះ | រូបមន្តស្ទើរលាត | ចំណុចរំពុះ (ºC) |
|---|---|---|
| អេតែន | $CH_2=CH_2$ | –104 |
| ប្រូប៉ែន | $CH_2=CH–CH_3$ | –47 |
| ប៊ុយ–1–អែន | $CH_2=CH–CH_2–CH_3$ | –6.5 |
| ប៉ង់–2–អែន | $CH_2=CH–CH_2–CH_2–CH_3$ | 30 |



RUPPDOC

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.១ ប្រតិកម្មចំហេះសព្វ

$$C_nH_{2n} + \frac{3n}{2} O_2 \rightarrow n\,CO_2 + n\,H_2O$$

អាល់សែន — កាបូនឌីអុកស៊ីត — ទឹក

- ឧទាហរណ៍៖
  - $C_2H_4 + O_2 \rightarrow$
  - $C_5H_{10} + O_2 \rightarrow$
  - $C_8H_{16} + O_2 \rightarrow$

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.២ ប្រតិកម្មបូក

ក. ប្រតិកម្មបូកជាមួយអ៊ីដ្រូសែនៈ អ៊ីដ្រូសែនកម្ម

**អាល់សែនបូកជាមួយ $H_2$ ដែលមាន Ni ជាកាតាលីករ**

$$C_nH_{2n} + H_2 \xrightarrow{Ni\ /\ t} C_nH_{2n+2}$$

អាល់សែន អាល់កាន

- ឧទាហរណ៍៖
  - $C_2H_4 + H_2 \rightarrow$
  - $CH_3\text{-}CH{=}CH_2 + H_2 \rightarrow$
  - $CH_3\text{-}CH{=}CH\text{-}CH_3 + H_2 \rightarrow$

12

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.២ ប្រតិកម្មបូក

ខ. ប្រតិកម្មបូកជាមួយអាឡូសែនៈ អាឡូសែនកម្ម

$$C_nH_{2n} + X_2 \rightarrow C_nH_{2n}X_2$$

អាល់សែន អាឡូសែន ឌីអាឡូសែណូអាល់កាន

- ឧទាហរណ៍៖
  - $C_2H_4 + Br_2 \rightarrow$
  - $CH_3\text{-}CH{=}CH_2 + Cl_2 \rightarrow$
  - $CH_3\text{-}CH{=}CH\text{-}CH_3 + Cl_2 \rightarrow$
- **ចំណាំៈ** គេប្រើទឹកប្រូម $Br_2$ សម្រាប់ធ្វើតេស្តរកវត្តមានអ៊ីដ្រូកាបួមិនទាន់ឆ្អែត អាល់សែន មានលក្ខណៈ បង្ហើរពណ៌ក្រហមត្នោតរបស់ទឹកប្រូម។

13

RUPPDOC

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.២ ប្រតិកម្មបូក

គ. ប្រតិកម្មបូកជាមួយអ៊ីដ្រូសែនអាឡូសែន (HX)

**បូកជាមួយអ៊ីដ្រូសែនអាឡូសែន**

$$C_nH_{2n} + HX \xrightarrow{HgCl_2} C_nH_{2n+1}X$$

អាល់សែន — អាឡូអាល់កាន

$$R{-}CH{=}CH_2 + H{-}Cl \xrightarrow{HgCl_2} R{-}CHCl{-}CH_3$$

- ឧទាហរណ៍៖
  - $C_2H_4 + HCl \rightarrow$
  - $CH_3\text{-}CH{=}CH_2 + HBr \rightarrow$



RUPPDOC

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.២ ប្រតិកម្មបូក

ឃ. ប្រតិកម្មបូកជាមួយទឹក៖ ប្រតិកម្មអ៊ីដ្រាតកម្ម

**ប្រតិកម្មបូកជាមួយទឹកតាមទ្រឹស្តី Markonikoff**

$$C_nH_{2n} + H_2O \xrightarrow{H_2SO_4/\ t^{\uparrow}} C_nH_{2n+1}OH$$

អាល់សែន — ម៉ូណូអាល់កុលឆ្អែត

$$R{-}CH{=}CH_2 + H_2O \xrightarrow{H_2SO_4/\ t^{\uparrow}} R{-}CHOH{-}CH_3$$

- ឧទាហរណ៍៖
  - $C_2H_4 + H_2O \rightarrow$
  - $CH_3\text{-}CH{=}CH_2 + H_2O \rightarrow$

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.៣ ប្រតិកម្មប៉ូលីមែរកម្ម

➢ ប្រតិកម្មប៉ូលីមែកម្ម គឺជាលំនាំប្រមូលផ្តុំម៉ូលេគុលតូចៗដូចគ្នាជាច្រើន ដើម្បីបង្កើតជា ម៉ូលេគុលដ៏ធំមួយ។

- ប្រតិកម្មប៉ូលីមែកម្មអេតែនៈ $C_2H_4 \rightarrow$
- ប្រតិកម្មប៉ូលីមែកម្មវីនីលក្លរៈ $CH_2{=}CH\text{-}Cl \rightarrow$
- ប្រតិកម្មប៉ូលីមែកម្មស្ទីរ៉ែន $CH_2{=}CH\text{-}Ph \rightarrow$
- ប្រតិកម្មប៉ូលីមែកម្មប្រូពីឡែន $CH_2{=}CH\text{-}CH_3 \rightarrow$



# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.៤ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួល

➢ អុកស៊ីតកម្ម $CH_2{=}CH_2$ ជាមួយអុកស៊ីសែននៃខ្យល់ ដែលមានល្បាយ $Ag_2O,Ag$ ជាកាតាលីករ។



គ្លីកុល

# ១. អាល់សែន

## ១.៦ ប្រតិកម្មគីមី

### ១.៦.៤ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួល

**អុកស៊ីតកម្មជាមួយ $KMnO_4$**

អាល់សែនបង្ហើរពណ៌ស្វាយនៃ $KMnO_4$

$$2KMnO_4 + 3C_nH_{2n} + 4H_2O \rightarrow 2KOH + 2MnO_2 + 3C_nH_{2n}(OH)_2$$

- ឧទាហរណ៍: $CH_2{=}CH_2$ បង្ហើរពណ៌ស្វាយនៃ $KMnO_4$





# ១. អាល់សែន

## ១.៧ ទទ្ធើ និងបម្រើបម្រាស់អាល់សែន

### ១.៧.១ ទទ្ធើអាល់សែន

### ក. ប្រតិកម្មដេស៊ីដ្រូសែនកម្មអាល់កាន

$$\underset{\text{អាល់កាន}}{C_nH_{2n+2}} \xrightarrow{Cr_2O_3\,/\,t} \underset{\text{អាល់សែន}}{C_nH_{2n}} + H_2$$

- ឧទាហរណ៍៖
  - $CH_3\text{-}CH_3 \rightarrow$
  - $CH_3\text{-}CH_2\text{-}CH_3 \rightarrow$
  - $CH_3\text{-}CH_2\text{-}CH_2\text{-}CH_3 \rightarrow$

# ១អាល់សែន

## ១.៧ ទង្វើ និងបម្រើបម្រាស់អាល់សែន

### ១.៧.១ ទង្វើអាល់សែន

### ខ. ក្រាគីញអាល់កាន

$$C_nH_{2n+2} \xrightarrow{t^{\circ}} C_xH_{2x} + C_yH_{2y+2}$$

អាល់កាន អាល់សែន អាល់កាន

- ឧទាហរណ៍៖
  - $C_4H_{10} \rightarrow C_2H_4 +$
  - $C_{12}H_{26} \rightarrow C_5H_{10} +$
  - $C_{18}H_{38} \rightarrow C_4H_8 + C_6H_{14} +$



# ១. អាល់សែន

## ១.៧ ទង្វើ និងបម្រើបម្រាស់អាល់សែន

### ១.៧.១ ទង្វើអាល់សែន

### គ. ដេស៊ីដ្រាតកម្មម៉ូណូអាល់កុល

$$C_nH_{2n+1}OH \xrightarrow{H_2SO_4,\ t > 40^{\circ}C} C_nH_{2n} + H_2O$$

អាល់កុល អាល់សែន

- ឧទាហរណ៍៖
  - $CH_2\text{-}CH_2\text{-}OH \rightarrow$
  - $CH_2\text{-}CH_2\text{-}CH_2\text{-}OH \rightarrow$
  - $CH_2\text{-}CH(OH)\text{-}CH_3 \rightarrow$

# ១. អាល់សែន

## ១.៧ ទង្វើ និងបម្រើបម្រាស់អាល់សែន

### ១.៧.២ បម្រើបម្រាស់អាល់សែន

ផលិតផលបានអំពីអង្គធាតុស្រឡាយអេតែន






# ២. អាល់ស៊ីន

## ២.១ សេចក្តីផ្តើម

- អាល់ស៊ីនជាអ៊ីដ្រូកាបួដែលមានសម្ព័ន្ធបីជាន់យ៉ាងតិចមួយនៅចន្លោះអាតូមកាបូន។
- អាល់ស៊ីន មានរូបមន្តទូទៅ $C_nH_{2n-2}$ ដែល $n \geq 2$ ។

| n | រូបមន្តទូទៅ $C_nH_{2n-2}$ | ឈ្មោះ |
|---|---|---|
| 2 | $C_2H_2$ | អេទីន |
| 3 | $C_3H_4$ | ប្រូពីន |
| 4 | $C_4H_6$ | ប៊ុយទីន |
| 5 | $C_5H_8$ | ប៉ង់ទីន |
| 6 | $C_6H_{10}$ | អិចស៊ីន |
| 7 | $C_7H_{12}$ | អិបទីន |
| 8 | $C_8H_{14}$ | អុកទីន |
| 9 | $C_9H_{16}$ | ណូនីន |
| 10 | $C_{10}H_{18}$ | ដេគីន |

RUPPDOC

# ២. អាល់ស៊ីន

## ២.២ នាមវលី

### ២.២.១ អាល់ស៊ីនដែលមានខ្សែកាបូនត្រង់

- ការហៅឈ្មោះអាល់ស៊ីនងាយ៖

$CH\equiv CH$ អេទីន ឬ អាសេទីឡែន $CH\equiv C-CH_3$ ប្រូពីន

- ចាប់ពី n ≥4 ការហៅឈ្មោះអាល់ស៊ីនត្រូវបង់លេខដូចអាល់សែនដែរ។

- ឧទាហរណ៍៖

$\overset{1}{C}H\equiv\overset{2}{C}-\overset{3}{C}H_2-\overset{4}{C}H_3$

ប៊ុយ-1-អ៊ីន

$\overset{1}{C}H_3-\overset{2}{C}\equiv\overset{3}{C}-\overset{4}{C}H_3$

ប៊ុយ-2-អ៊ីន

$\overset{1}{C}H\equiv\overset{2}{C}-\overset{3}{C}H_2-\overset{4}{C}H_2-\overset{5}{C}H_3$

ប៉ង់-1-អ៊ីន

$\overset{1}{C}H_3-\overset{2}{C}\equiv\overset{3}{C}-\overset{4}{C}H_2-\overset{5}{C}H_3$

ប៉ង់-2-អ៊ីន



RUPPDOC

# ២. អាល់ស៊ីន

## ២.២ នាមវលី

### ២.២.២ អាល់ស៊ីនដែលមានខ្សែកាបូនត្រង់

- ការហៅឈ្មោះអាល់ស៊ីនខ្សែកាបូនខ្នែងត្រូវធ្វើតាមជំហានខាងក្រោម៖




- ឧទាហរណ៍៖

$\overset{1}{C}H\equiv\overset{2}{C}-\overset{3}{C}H(CH_3)-\overset{4}{C}H_3$

3–មេទីលប៊ុយ–1–អ៊ីន

$\overset{1}{C}H_3-\overset{2}{C}\equiv\overset{3}{C}-\overset{4}{C}H(CH_3)-\overset{5}{C}H(CH_3)-\overset{6}{C}H_3$

4,5–ឌីមេទីលអិច–2–អ៊ីន

# ២. អាល់ស៊ីន

## ២.២ នាមវលី

➢ អនុវត្តន៍៖ ចូរហៅឈ្មោះសមាសធាតុខាងក្រោម៖




➢ អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើរលាតរបស់សមាសធាតុខាងក្រោម៖

ក.4,5–ឌីមេទីលអិច–1–អ៊ីន      ខ. 2–អេទីល–5–មេទីលអិច–3–អ៊ីន

គ.4–មេទីលប៉ិុយ–1–អ៊ីន      ឃ.ប៉ិុយ–2–អ៊ីន



# ២. អាល់ស៊ីន

## ២.៣ ទម្រង់ម៉ូលេគុលអាល់ស៊ីនខាយ

➢ អេទីន ឬអាសេទីឡែន៖

$HC\equiv CH$ — រូបមន្តស្ទើរលាត

$H-C\equiv C-H$ — រូបមន្តម៉ូលេគុល



គម្រូឃ្លាតម៉ូលេគុល

➢ ប្រូពីន៖

ប្រូពីន

$HC\equiv C-CH_3$ — រូបមន្តស្ទើរលាត




រូបមន្តម៉ូលេគុល



គម្រូឃ្លាតម៉ូលេគុល

RUPPDOC

# ២. អាល់ស៊ីន

## ២.៤ អ៊ីសូមែ

- ដើម្បីសរសេរអ៊ីសូមែរបស់អាល់ស៊ីនគេត្រូវយកអ៊ីសូមែនៃអាល់កានដែលត្រូវនឹងវាមកបន្ថែមសម្ព័ន្ធបីជាន់ចំនួនមួយ។
- ឧទាហរណ៍៖ អ៊ីសូមែរ និងឈ្មោះរបស់អាល់ស៊ីនដែលមានរូបមន្តម៉ូលគុល$C_5H_8$



RUPPDOC

# ២. អាល់ស៊ីន

## ២.៤ អ៊ីសូមែ

➢ អនុវត្តន៍៖ សរសេររូបមន្តស្ទើរលាត, ហៅឈ្មោះ និងបញ្ជាក់ទំនងអ៊ីសូមែរទាំងអស់របស់$C_6H_{10}$ :

RUPPDOC

# ២. អាល់ស៊ីន

## ២.៥ លក្ខណៈរូប

- អាសេទីឡែនជាឧស្ម័នគ្មានពណ៌ ស្រាលជាងខ្យល់ និងរលាយក្នុងទឹកបានតិចតួច។
- សីតុណ្ហភាពរំពុះរបស់អាល់ស៊ីនកើនឡើងទៅតាមចំនួនអាតូមកាបូន។

| ឈ្មោះ | រូបមន្តស្ទើរលាត | ចំណុចរំពុះ (ºC) |
|---|---|---|
| អេទីន | $CH\equiv CH$ | –84 |
| ប្រូពីន | $CH\equiv C–CH_3$ | –23 |
| ប៊ុយ–1–អ៊ីន | $CH\equiv C–CH_2–CH_3$ | 8 |
| ប៉ង់–2–អ៊ីន | $CH\equiv C–CH_2–CH_2–CH_3$ | 39 |



RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.១ ប្រតិកម្មចំហេះ

$$C_nH_{2n-2} + (\frac{3n-1}{2})O_2 \rightarrow nCO_2 + (n-1)H_2O$$

អាល់ស៊ីន កាបូនឌីអុកស៊ីត ទឹក

- ឧទាហរណ៍៖
    - $C_2H_2 + O_2 \rightarrow$
    - $CH_3\text{-}C\equiv CH + O_2 \rightarrow$
    - $CH_3\text{-}C\equiv CH\text{-}CH_2\text{-}CH_3 + O_2 \rightarrow$

RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.២ ប្រតិកម្មបូក

ក. ប្រតិកម្មបូកអ៊ីដ្រូសែន៖ ប្រតិកម្មអ៊ីដ្រូសែនកម្ម

$$C_nH_{2n-2} + 2H_2 \xrightarrow{Ni \text{ ឬ } Pt} C_nH_{2n+2}$$

អាល់ស៊ីន អ៊ីដ្រូសែន អាល់កាន

➢ ឧទាហរណ៍៖ ក្រោមអំពើនៃកាតាលីករ Ni ឬ Pt និងដុតកម្ដៅ៖

- $C_2H_2 + H_2 \rightarrow$
- $CH_3\text{-}C{\equiv}CH + H_2 \rightarrow$
- $CH_3\text{-}C{\equiv}CH\text{-}CH_2\text{-}CH_3 + H_2 \rightarrow$



RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.២ ប្រតិកម្មបូក

ខ. ប្រតិកម្មបូកអាឡូសែន៖ ប្រតិកម្មអាឡូសែនកម្ម

$$C_nH_{2n-2} + 2X_2 \rightarrow C_nH_{2n-2}X_4$$

អាល់ស៊ីន អាឡូសែន តេត្រាអាឡូសែណូអាល់កាន

➢ ឧទាហរណ៍៖

- $C_2H_2 + Br_2 \rightarrow$
- $CH_3\text{-}C{\equiv}CH + Cl_2 \rightarrow$
- $CH_3\text{-}C{\equiv}C\text{-}CH_2\text{-}CH_3 + Br_2 \rightarrow$

RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.២ ប្រតិកម្មបូក

#### គ. ប្រតិកម្មជាមួយទឹក៖ ប្រតិកម្មអ៊ីដ្រាតកម្ម

$$R{-}C{\equiv}CH + H_2O \xrightarrow{HgSO_4,\ t^\circ} R{-}CH_2{-}CHO$$

អាល់ស៊ីន → អាល់ដេអ៊ីត

$$R_1{-}C{\equiv}C{-}R_2 + H_2O \xrightarrow{HgSO_4,\ t^\circ} R_1{-}CH_2{-}CO{-}R_2$$

អាល់ស៊ីន → សេតូន

- ឧទាហរណ៍៖
  - $C_2H_2 + H_2O \rightarrow$
  - $CH_3{-}C{\equiv}CH + H_2O \rightarrow$
  - $CH_3{-}C{\equiv}C{-}CH_3 + H_2O \rightarrow$



RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.២ ប្រតិកម្មបូក

#### ឃ. ប្រតិកម្មជាមួយឧស្ម័នHCl

$$C_nH_{2n-2} + HCl \xrightarrow{HgCl_2} C_nH_{2n-1}Cl$$

អាល់ស៊ីន → ក្លរ៉ូអាល់សែន

- ឧទាហរណ៍៖ ក្រោមអំពើនៃកាតាលីករ $HgCl_2$៖
  - $C_2H_2 + HCl \rightarrow$
  - $CH_3{-}C{\equiv}CH + HCl \rightarrow$
  - $CH_3{-}C{\equiv}C{-}CH_3 + HCl \rightarrow$

RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.៤ ប្រតិកម្មជំនួស

#### ក. សូលុយស្យុង $AgNO_3$ /$NH_4OH$

- ល្បាយសូលុយស្យុង $AgNO_3$ /$NH_4OH$ បង្កើតបានសូលុស្យុង មួយទៀតគឺ $Ag(NH_3)_2^+$ ដែលហៅថារ៉េអាក់ទីបតូឡង់Tollen។

$$2AgNO_3 + 2NH_4OH \rightarrow 2AgOH + 2NH_4NO_3$$
$$2AgOH + 4NH_4OH \rightarrow 2Ag(NH_3)_2OH + 4H_2O$$

$$2AgNO_3 + 6NH_4OH \rightarrow 2Ag(NH_3)_2OH + 2NH_4NO_3 + 4H_2O$$



RUPPDOC

# ២. អាល់ស៊ីន

## ២.៦ លក្ខណៈគីមី

### ២.៦.៤ ប្រតិកម្មជំនួស

#### ខ. ប្រតិកម្មរវាង អាល់ស៊ីនមួយចំនួនជាមួយរ៉េអាក់ទីបតូឡង់

- ពេលគេឱ្យឧស្ម័ន CH≡CH ឆ្លងកាត់ សូលុយស្យុង $Ag(NH_3)_2^+$ គេទទួលបានកករពណ៌លឿងខ្ចី។

$$CH{\equiv}CH + 2Ag(NH_3)_2^+ \rightarrow Ag{-}C{\equiv}C{-}Ag\ (s) + 2NH_3\ (g) + 2NH_4^+$$

ប្រាក់អាសេទីឡែន

កករលឿងខ្ចី

# ២. អាល់ស៊ីន

## ២.៧ ទង្វើ និងបម្រើបម្រាស់

### ២.៧.១ ទង្វើអាល់ស៊ីន

- ទង្វើអាសេទីឡែន ពី ថ្មស្អុយ៖

$$CaC_2 + 2H_2O \rightarrow CH\equiv CH + Ca(OH)_2$$

កាល់ស្យូមកាបួ → អាសេទីឡែន

❖ $CaC_2$ បានពីថ្មកំបោរ

$$CaCO_3 \xrightarrow{1200°C} CaO + CO_2\ (g)$$

ថ្មកំបោរ → កំបោររស់

$$CaO + 3C \xrightarrow{3000°C} CaC_2 + CO\ (g)$$



# ២. អាល់ស៊ីន

## ២.៧ ទង្វើ និងបម្រើបម្រាស់

### ២.៧.១ ទង្វើអាល់ស៊ីន

- ទង្វើអាសេទីឡែនពីឧស្ម័នមេតាន $CH_4$

$$2CH_4 \xrightarrow{1500°C\ /\ \text{ឡអគ្គីសនី}} CH\equiv CH + 3H_2$$

- ទង្វើអាសេទីឡែន ពី C និង $H_2$

$$2C + H_2 \xrightarrow{3000°C} CH\equiv CH$$

# ២. អាល់ស៊ីន

## ២.៧ ទង្វើ និងបម្រើបម្រាស់

### ២.៧.២ បម្រើបម្រាស់




- កាលពីមុនគេប្រើអេទីនជាវត្ថុធាតុដើមយ៉ាងសំខាន់ សម្រាប់សំយោគសរសៃអំបោះ និងកៅស៊ូ។ តែពេលនេះគេប្រើ អេតែនជំនួសវិញ។
- គេប្រើអាសេទីឡែនជាធាតុក្នុងជំពុះផ្សារ អុកស៊ីអាសេទីឡែនសម្រាប់កាត់ ឬផ្សារលោហះ។



# លំហាត់គំរូទី១

អាល់សែនមួយមានម៉ាសម៉ូល 56g/mol ។

ក.ចូរកំណត់រូបមន្តដុលនៃអាល់សែននេះ។

ខ.ចូរសរសេរអ៊ីសូមែដែលអាចមានចំពោះអាល់សែននេះ។

RUPPDOC

# លំហាត់គំរូទី២

អាល់សែនមួយមានម៉ាស4.2g និងមានចំនួនម៉ូល 0.06mol ។

ក.ចូរកំណត់រូបមន្តដុលនៃអាល់សែននេះ។

ខ.ចូរសរសេរសមីការតាងប្រតិកម្មចំហេះសព្វនៃអាល់សែននេះ។

គ.គណនាម៉ាស$CO_2$ ដែលកកើត។



RUPPDOC

# ដំណោះស្រាយ

RUPPDOC

# ដំណោះស្រាយ



RUPPDOC

# លំហាត់គំរូទី៣

គេយក5.8gនៃអាល់ស៊ីនXមានអំពើជាមួយទឹកប្រូមចំនួន100mLកំហាប់2M។

ចូរកំណត់ រូបមន្តម៉ូលេគុលនៃអាល់ស៊ីននេះ។?

# ដំណោះស្រាយ

RUPPDOC

# លំហាត់គំរូទី៤

គេចង់ធ្វើអាសេទីឡែន 52g ពីកាល់ស្យូមកាប៊ួ ដែលមានភាគរយសុទ្ធ90%។ តើគេត្រូវការកាល់ស្យូមកាប៊ួនេះប៉ុន្មានក្រាម បើទិន្នផលនៃប្រតិកម្មមានត្រឹមតែ 75% ?

## ដំណោះស្រាយ



RUPPDOC

# មេរៀនទី៣

# អ៊ីដ្រូកាបួប្រហើរ៖ បង់សែន

RUPPDOC

# វត្ថុបំណង

**ក្នុងមេរៀននេះយើងនឹងអាច៖**

១ • គូរទម្រង់ និងហៅឈ្មោះរបស់ស្រលាយបង់សែន

២ • រៀបរាប់លក្ខណៈរូប និងប្រតិកម្មសំខាន់ៗរបស់បង់សែន និង ស្រលាយរបស់វា

៣ • រៀបរាប់អំពីទង្វើ និងបម្រើបម្រាស់របស់បង់សែន និង ស្រលាយរបស់វា

2

RUPPDOC

# ១. អ៊ីដ្រូកាបួប្រហើរ

- **អ៊ីដ្រូកាបួប្រហើរ** គឺជាអ៊ីដ្រូកាបួដែលមានណ្វៃយ៉ូបង់សែននៅក្នុងនោះ។ អ៊ីដ្រូកាបួប្រហើរដែលសំខាន់ជាងគេបំផុតគឺបង់សែន។
- បង់សែនជាសមាសធាតុប្រហើរមួយដែលមានរូបមន្តម៉ូលេគុល $C_6H_6$ ។ វាជាអ៊ីដ្រូកាបួមិនទាន់ឆ្អែតខ្លាំង។




និមិត្តសញ្ញាបង់សែនបែបចាស់




និមិត្តសញ្ញាបង់សែនបែបថ្មី

3

# ២. នាមវលី



$C_6H_6$
បង់សែន



$C_6H_5-$
ផេនីល



$C_6H_5-CH_2-$
បង់ស៊ីល

## ២.១ ការហៅឈ្មោះស្រឡាយបង់សែនដែលមានបណ្តុំជំនួសតែមួយ

- ដើម្បីហៅឈ្មោះបង់សែនដែលមានក្រុមជួសតែមួយ ត្រូវហៅឈ្មោះក្រុមជួសមុនសិនរួច ហៅបង់សែន។ ឈ្មោះបណ្តុំជំនួសអាចជាៈ $NO_2$ នីត្រូ $NH_2$ អាមីណូ OH អ៊ីដ្រុកស៊ីល Cl ក្លរ៉ូ Br ប្រូម៉ូ $CH_3$ មេទីល $CH_2CH_3$ អេទីល $CH=CH_2$ វីនីល ...។



# ២. នាមវលី

## ២.១ ការហៅឈ្មោះស្រឡាយបង់សែនដែលមានបណ្តុំជំនួសតែមួយ

ការហៅឈ្មោះស្រឡាយបង់សែនៈ ឈ្មោះបណ្តុំជំនួស + បង់សែន



ប្រូម៉ូបង់សែន



នីត្រូបង់សែន



ក្លរ៉ូបង់សែន



អេទីលបង់សែន



មេទីលបង់សែន
ឬ តូលុយអែន



អ៊ីដ្រុកស៊ីបង់សែន
ឬ ផេណុល



អាមីណូបង់សែន
ឬ អានីលីន



វីនីលបង់សែន
ឬ ស្ទីរ៉ែន

# ២. នាមវលី

## ២.២ ការហៅឈ្មោះស្រឡាយបង់សែនដែលមានបណ្ដុំជំនួសពីរ




1,2–ឌីក្លរ៉ូបង់សែន
o–ឌីក្លរ៉ូបង់សែន




1,3–ឌីក្លរ៉ូបង់សែន
m–ឌីក្លរ៉ូបង់សែន




1,4–ឌីក្លរ៉ូបង់សែន
p–ឌីក្លរ៉ូបង់សែន




1–ប្រូម៉ូ–3–ក្លរ៉ូបង់សែន
m–ប្រូម៉ូក្លរ៉ូបង់សែន




1–អ៊ីយ៉ូដូ–3–នីត្រូបង់សែន
m–អ៊ីយ៉ូដូនីត្រូបង់សែន




4–នីត្រូតូលុយអែន
p–នីត្រូតូលុយអែន




3–ក្លរ៉ូផេណុល
m–ក្លរ៉ូផេណុល




2–អេទីលអានីលីន
o–អេទីលអានីលីន



# ២. នាមវលី

## ២.៣ ការហៅឈ្មោះស្រឡាយបង់សែនដែលមានបណ្ដុំជំនួសច្រើនជាងពីរ

- ដើម្បីហៅឈ្មោះស្រឡាយបង់សែនដែលមានបណ្ដុំជំនួសលើសពីពីរ យើងត្រូវប្រើប្រព័ន្ធបង់ លេខ និងបង់លេខយ៉ាងណាឱ្យក្រុមជួសទាំងអស់មានលេខតូចបំផុត។




1,3,5–ទ្រីក្លរ៉ូបង់សែន




3,5–ឌីក្លរ៉ូតូលុយអែន




2,4,6–ទ្រីនីត្រូតូលុយអែន (T.N.T)

# ២. នាមវលី

➢ អនុវត្តន៍៖ ចូរឱ្យឈ្មោះសមាសធាតុដែលមានរូបមន្តស្ទើរលោតដូចខាងក្រោម៖

ក. 


ខ. 


គ. 


ឃ. 


ង. 




២. នាមវលី

➢ អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើរលោតដូចខាងក្រោម៖

ក. ផេនីលអាសេទីឡែន ខ.1–ផេនីលប្រូពីន

គ.1–ផេនីលប៊ុយ–1–អ៊ីន ឃ.(Z)–1–ផេនីលប្រូប៉ែន

ង.(E)–1–ផេនីលប្រូប៉ែន ច.2–ក្លរ៉ូ–1–ផេនីលប្រូប៉ាន

ឆ.បង់ស៊ីលក្លរ ជ.មេទីលបង់សែន

## ៣. លក្ខណៈរូប

- បង់សែន ជាអង្គធាតុរាវ ថ្លា គ្មានពណ៌ មានក្លិនក្រអូប។ ងាយហួតចូលទៅក្នុងខ្យល់ ងាយឆាបឆេះ និងរលាយតិចតួចក្នុងទឹក។ មានម៉ាសម៉ូល 78.11g/mol សី.កំណក 5.5°C និងសី.រំពុះ 80.1°C ។



## ៤. អូម៉ូឡូកបង់សែន និងទម្រង់របស់វា

- **អូម៉ូឡូកបង់សែន**បានមកពីការជំនួសអាតូម អ៊ីដ្រូសែនមួយ ឬច្រើន របស់បង់សែន ដោយរ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត។ ដែលមានរូបមន្តទូទៅ $C_nH_{2n-6}$ $n \geq 6$




ដែល $R_1$ $R_2$ $R_3$ $R_4$ $R_5$ $R_6$ ជារ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត

RUPPDOC

# ៥. អ៊ីសូមែ

- ដើម្បីសរសេររូបមន្តស្ទើរលាតនៃអ៊ីសូមែដែលជាអូម៉ូឡូកបង់សែន គេត្រូវសរសេរណ្វៃយ៉ូបង់សែនបន្ទាប់មកទើបគេភ្ជាប់ រ៉ាឌីកាល់អ៊ីដ្រូកាបូឆ្អែត ទៅលើណ្វៃយ៉ូបង់សែន។

- ឧទាហរណ៍៖ សរសេររូបមន្តស្ទើរលាត និងហៅឈ្មោះរបស់ស្រលាយបង់សែនដែលមានរូបមន្តម៉ូលេគុល$C_8H_{10}$



RUPPDOC

# ៦. លក្ខណៈគីមី

## ៦.១ ប្រតិកម្មចំហេះ

$$C_6H_6 + \frac{15}{2}O_2 \rightarrow 6CO_2 + 3H_2O$$

## ៦.២ ប្រតិកម្មជំនួស

### ៦.២.១ ប្រូមកម្មអាល់សែន

- បង់សែនគ្មានអំពើជាមួយទឹកប្រូម ប៉ុន្តែបើគេឱ្យបង់សែនមានអំពើជាមួយប្រូមរាវសុទ្ធនៅចំពោះនៅចំពោះមុខកាតាលីករដែក ពេលនោះប្រតិកម្មជំនួសនឹងកើតមានឡើងភ្លាមបង្កើតបាន ជាប្រូម៉ូបង់សែន និងឧស្ម័នHBr ។




បង់សែន ប្រូម៉ូបង់សែន

# ៦. លក្ខណៈគីមី

## ៦.២ ប្រតិកម្មជំនួស

### ៦.២.២ ក្លរ៉ូកម្មបង់សែន




បង់សែន ក្លរ៉ូបង់សែន



# ៦. លក្ខណៈគីមី

## ៦.២ ប្រតិកម្មជំនួស

### ៦.២.៣ ប្រតិកម្មនីទ្រកម្ម

- ប្រតិកម្មនីទ្រកម្មគឺជាប្រតិកម្មជំនួសអាតូមអ៊ីដ្រូសែនមួយ ឬច្រើនរបស់អ៊ីដ្រូកាបួណាមួយ ដោយបង្គុំនីត្រូ($NO_2$) របស់អាស៊ីតនីទ្រិច ($HONO_2$)ខាប់ ដែលមានអាស៊ីតស៊ុលផួរិច ($H_2SO_4$)ខាប់ ជាកាតាលីករ។




បង់សែន នីត្រូបង់សែន

តូលុយអែន ទ្រីនីត្រូបង់សែន (TNT)

# ៦. លក្ខណៈគីមី

## ៦.២ ប្រតិកម្មជំនួស

### ៦.២.៤ ប្រតិកម្មអាល់គីលកម្ម

➢ បង់សែនមានប្រតិកម្មជំនួសជាមួយអាល់គីលអាឡូសែនក្នុងវត្តមានកាតាលីករដែក(III)ក្លរួ ឬ ដែក (III)ប្រូម៊ួ។




បង់សែន អាល់គីលអាឡូសែន អាល់គីលបង់សែន

➢ ឧទាហរណ៍៖






# ៦. លក្ខណៈគីមី

## ៦.២ ប្រតិកម្មជំនួស

### ៦.២.៥ ប្រតិកម្មស៊ុលផូនកម្ម

➢ បង់សែនមានប្រតិកម្មជំនួសជាមួយចំហាយអាស៊ីតស៊ុលផួរិចខាប់នៅសីតុណ្ហភាពបន្ទប់ បង្កើតជាអាស៊ីតបង់សែនស៊ុលផូនិច ដែលត្រូវបានហៅថាប្រតិកម្មស៊ុលផូនកម្ម។




បង់សែន អាស៊ីតបង់សែនស៊ុលផូនិច

# ៦. លក្ខណៈគីមី

## ៦.៣ ប្រតិកម្មបូក

### ៦.៣.១ ប្រតិកម្មបូកជាមួយក្លរ

- បង់សែនមានប្រតិកម្មបូកជាមួយក្លរ ($Cl_2$) ក្នុងលក្ខណ្ឌពន្លឺសាយ




1,2,3,4,5,6–អិចសាក្លរ៉ូស៊ីក្លូអិចសាន



# ៦. លក្ខណៈគីមី

## ៦.៣ ប្រតិកម្មបូក

### ៦.៣.២ ប្រតិកម្មបូកជាមួយ$H_2$

- បង់សែនមានប្រតិកម្មបូកជាមួយ$H_2$ នៅចំពោះមុខកាតាលីករនីកែល។




កម្តៅ ស៊ីក្លូអិចសាន

- បង់សែនមានលក្ខណៈដូចអ៊ីដ្រូកាបួមិនទាន់ឆ្អែត តែវាពិបាកនឹងមានប្រតិកម្មបូកជាងអ៊ីដ្រូកាបួមិនទាន់ឆ្អែត។

# ៦. លក្ខណៈគីមី

## ៦.៤ ប្រតិកម្មអុកស៊ីតកម្មទៅលើស្រលាយបង់សែន

### ៦.៤.១ អុកស៊ីតកម្មតូលុយអែនដោយសូលុយស្យុង$KMnO_4$ក្នុងមជ្ឈដ្ឋាន$H_2SO_4$




តូលុយអែន អាស៊ីតបង់សូអ៊ិច

### ៦.៤.២ អុកស៊ីតកម្មស្ទីរ៉ូឡែនដោយសូលុយស្យុង$KMnO_4$ ក្នុងមជ្ឈដ្ឋានបាស




1–ផេនីលអេតាន–1,2–ឌីអុល



# ៧.អ៊ីដ្រូកាបួប្រហើរពហុវង់

 ឬ 

ណាប់តាឡែន



អង់ត្រាសែន



ផេណង់ត្រែន

## ៨. ទទ្វើ និងបម្រើបម្រាស់

- ប្រភពបង់សែនដែលប្រើប្រាស់សព្វថ្ងៃនេះ បានមកពីឧស្សាហកម្មកូកេកម្មធ្យូងថ្ម។
- សព្វថ្ងៃនេះប្រទេសជាច្រើននៅក្នុងពិភពលោកបានទង្វើបង់សែនពីប្រតិកម្មដេស៊ីដ្រូសែនកម្ម ស៊ីក្លូអិចសាននៅចំពោះមុខកាតាលីករPd និងPt នៅសីតុណ្ហភាពប្រមាណ300°C។




ស៊ីក្លូអិចសាន បង់សែន



## ៨. ទទ្វើ និងបម្រើបម្រាស់

- គេទង្វើបង់សែនពីn–អិចសាន តាមប្រតិកម្មដេស៊ីដ្រូសែនកម្ម នៅចំពោះមុខកាតាលីករPt នៅសីតុណ្ហភាពខ្ពស់។




- បង់សែនត្រូវបានសំយោគពីអាសេទីឡែន កាតាលីករ Fe ឬ Cu ក្តៅ៖




- បង់សែនជាវត្ថុធាតុដើម្រាប់សំយោគ នីត្រូបង់សែន ក្លរ៉ូបង់សែន ល័ខ ថ្នាំពេទ្យ ប្លាស្ទិច ស្ពោ និងជាតុរំលាយសរីរាង្គ។

RUPPDOC

# លំហាត់គំរូទី១

ចូរសរសេរអ៊ីសូមែចំនួន៤ ដែលជាទម្រង់ស្មើរលោតនៃ

ក.ឌីមេទីលបង់សែន ខ.តេត្រាមេទីលបង់សែន គ.ឌីមេទីលផេណុល

# ដំណោះស្រាយ



RUPPDOC

# លំហាត់គំរូទី២

ចេញពីបង់សែនចូរសរសេរសមីការតុល្យការសំយោគអង្គធាតុខាងក្រោមៈ

ក.អិចសាក្លរ៉ូស៊ីក្លូអិចសាន ខ.ស៊ីក្លូអិចសាន គ.ក្លរ៉ូបង់សែន

ឃ.ប្រូម៉ូបង់សែន ង.នីត្រូបង់សែន ច.តូលុយអែន

ឆ.o–នីត្រូតូលុយអែន

# ដំណោះស្រាយ

RUPPDOC

# លំហាត់គំរូទី៣

ចំហេះសព្វ1.3g នៃអ៊ីដ្រូកាបួគេទទួលបានទឹក0.9g ។

ក.ចូរកំណត់រូបមន្តងាយនៃអ៊ីដ្រូកាបួនេះ។

ខ.ដង់ស៊ីតេនៃអ៊ីដ្រូកាបួនេះធៀបនឹងខ្យល់ស្មើនឹង 3.59។ ចូរកំណត់រូបមន្តម៉ូលេគុល និងរូបមន្តស្ទើរលាត បើវាជាស្រទ្បាយនៃបង់សែន។



RUPPDOC

# ដំណោះស្រាយ

# ជំពូកទី២

# ស្តេរ៉េអូគីមី

## មេរៀនទី១

# ធរណីមាត្រនៃម៉ូលេគុល

1

## វត្ថុបំណង

### ក្នុងមេរៀននេះយើងនឹងអាច៖

- គូរទម្រង់ឡឺវីសនៃអាតូម ម៉ូលេគុល និងអ៊ីយ៉ុង
- កំណត់ធរណីមាត្រម៉ូលេគុលឬអ៊ីយ៉ុងដោយប្រើវិធីចម្រាន គូអេឡិចត្រុងស្រទាប់វ៉ាឡង់ VSEPR

2

# ១. តំនួសតាងឡឺវីស

## ១.១.ទម្រង់ឡឺវីសនៃអាតូម

- តំនួសតាងឡឺវីសតាងស្រទាប់ក្រៅនៃអាតូមដោយទ្វេតាអេឡិចត្រុង និងអេឡិចត្រុងសេរី។ ទ្វេតាអេឡិចត្រុងតាងរង្វសញ្ញា(-)និងតាងអេឡិចត្រុងមិនដាក់ហ៊ុនដោយចំណុច (·)មួយ។






# ១. តំនួសតាងឡឺវីស

## ១.២ សម្ព័ន្ធកូវ៉ាឡង់

- សម្ព័ន្ធកូវ៉ាឡង់គឺ ជាការដាក់អេឡិចត្រុងទោលរួមគ្នារវាងអាតូមពីរ។
- ទ្វេតាអេឡិចត្រុងរួមនេះ ហៅថា ទ្វេតាសម្ព័ន្ធ ឬទ្វេតាអេឡិចត្រុងសម្ព័ន្ធ ឬគូអេឡិចត្រុងសម្ព័ន្ធ ដែលគេតាងដោយរង្វសញ្ញា នៅចន្លោះនិមិត្តសញ្ញាអាតូមពីរ។
- ឧទាហរណ៍៖






# ១. គំនូសតាងឡឺវីស

## ១.៣.វិធានអដ្ឋតា

- ច្បាប់អដ្ឋតា: គ្រប់អាតូមទាំងអស់មានទំនោរធ្វើឲ្យស្រទាប់ក្រៅបង្អស់របស់វាឆ្អែតគឺ8e ឬ មួយអដ្ឋតាអេឡិចត្រុង(លើកលែងតែ Heនិង $H_2$)។




- សម្គាល់: មានករណីលើកលែងខ្លះចំពោះវិធានអដ្ឋតា។
- ឧទាហរណ៍៖ $AlCl_3$ $PCl_5$ $SO_3$












# ១. គំនូសតាងឡឺវីស

## ១.៤.ការបង្កើតទម្រង់ឡឺវីស

### ក. និយមន័យ

- ទម្រង់ឡឺវីសគឺជាការតាងម៉ូលេគុល ឬអ៊ីយ៉ុងប៉ូលីអាតូម ដើម្បីបង្ហាញការបន្តអាតូម ទាំងឡាយក្នុងម៉ូលេគុល ឬអ៊ីយ៉ុង និងបង្ហាញអេឡិចត្រុងនៅស្រទាប់វ៉ាឡង់ ដោយបែងចែកគូអេឡិចត្រុងសេរី និងគូអេឡិចត្រុងសម្ព័ន្ធ។
- ទ្វេតាអេឡិចត្រុងតាងដោយរផ្ទុសញ្ញា(-) អេឡិចត្រុងមិនដាក់ហ៊ុនតាងដោយចំណុច(·)មួយ និងបន្តអាតូមហៅថា ទ្វេតាសម្ព័ន្ធ ។
- ឧទាហរណ៍៖ $BH_2$ $OH^-$ $H_2O$









RUPPDOC

# ១. គំនូសតាងឡឺវីស

## ១.៤.ការបង្កើតទម្រង់ឡឺវីស

## ខ. សំណេរទម្រង់ឡឺវីស

- ការសរសេរទម្រង់ឡឺវីសមាន៤ដំណាក់កាល៖

1. របៀបបន្តអាតូមៈ អាតូមម៉ូណូវ៉ាឡង់ទាំងអស់ត្រូវស្ថិតនៅចុងអាតូមដែលមានវ៉ាឡង់ច្រើន ជាងគេនៅកណ្ដាល។

ឧទាហរណ៍ៈ HClO H មានវ៉ាឡង់1 Clមានវ៉ាឡង់1 Oមានវ៉ាឡង់2 នោះ O ជាអាតូមកណ្ដាល H និង Clជាអាតូមនៅចុង។ HOCl

7

RUPPDOC

# ១. គំនូសតាងឡឺវីស

## ១.៤.ការបង្កើតទម្រង់ឡឺវីស

## ខ. សំណេរទម្រង់ឡឺវីស

2. របាយទ្វេតាអេឡិចត្រុងៈ

$X_1$ តាងផលបូកអេឡិចត្រុងសេរីក្នុងម៉ូលេគុល

$X_2$ តាងផលបូកអេឡិចត្រុងបំពេញស្រទាប់ក្រៅផ្ទៃត

$L=\frac{X_2-X_1}{2}$ (Lតាងទ្វេតាសម្ព័ន្ធ) $D=\frac{X_1}{2}-L$ (Dតាងទ្វេតាអេឡិចត្រុងសេរី)

ឧទាហរណ៍ៈ HClO

$X_1 = 1 + 7 + 6 = 14é$ $L=\frac{X_2-X_1}{2}=\frac{18-14}{2}=2$ ទ្វេតាសម្ព័ន្ធ

$X_2 = 2 + 8 + 8 = 18é$ $D=\frac{X_1}{2}-L=\frac{14}{2}-2=5$ ទ្វេតាអេឡិចត្រុង




8

# ១. គំនូសតាងឡឺវីស

## ១.៤.ការបង្កើតទម្រង់ឡឺវីស

### ខ. សំណេរទម្រង់ឡឺវីស

3. ការកំណត់បន្ទុកជាក់លាក់

បន្ទុកជាក់លាក់ = អេឡិចត្រុងវ៉ាឡង់ -½អេឡិចត្រុងសម្ព័ន្ធ - អេឡិចត្រុងមិនសម្ព័ន្ធ

ឧទាហរណ៍: $CO_3^{2-}$ $O_3$ $NH_4^+$

9

# ១. គំនូសតាងឡឺវីស

## ១.៤.ការបង្កើតទម្រង់ឡឺវីស

### ខ. សំណេរទម្រង់ឡឺវីស

4. លក្ខណៈវិនិច្ឆ័យនៃជម្រើសរវាងទម្រង់ឡឺវីសច្រើន៖ ទម្រង់ឡឺវីសត្រឹមត្រូវគឺអាតូមទាំងអស់គោរពតាមវិធានអដ្ឋតា។ បើមានរូបមន្តច្រើនគោរព តាមវិធានអដ្ឋតា គេត្រូវជ្រើសរើសយកទម្រង់ដែលមានបន្ទុកជាក់លាក់តូចជាងគេ។

ឧទាហរណ៍: ទម្រង់ឡឺវីសកាបូនម៉ូណូអុកស៊ីត CO



10

# ១. គំនូសតាងឡឺវីស

អនុវត្តន៍៖ ចូរគូរទម្រង់ឡឺវីសរបស់

ក.$H_2S$ ខ.$PH_3$ គ.$CHCl_3$ ឃ.$CH_3OH$ ង.$HCO_3^-$ ច.$CO_3^{2-}$ ឆ. $HPO_4^{2-}$



# ២.ធរណីមាត្រនៃម៉ូលេគុលនិងអ៊ីយ៉ុង

## ២.១.វិធី VSEPR

- VSEPR ពាក្យពេញ Valence Shell Electron Pair Repulsion មានន័យថា៖ ចម្រានគូអេឡិចត្រុងនៃ ស្រទាប់វ៉ាឡង់។
- វិធីនេះប្រាប់ឱ្យយើងដឹងពីទីតាំងក្នុងលំហនៃគូអេឡិចត្រុងនៅជុំវិញអាតូមកណ្តាលរបស់ម៉ូលេគុល ឬអ៊ីយ៉ុង។

ឧទាហរណ៍៖ $CH_4$ $NH_3$



RUPPDOC

# ២.ធរណីមាត្រនៃម៉ូលេគុលនិងអ៊ីយ៉ុង

## ២.២.គោលការណ៍នៃវិធី VSEPR

និមិត្តសញ្ញាម៉ូលេគុល $AX_mE_n$

A ជាអាតូមកណ្តាល

X ជាអាតូមដែលភ្ជាប់អាតូមA មានចំនួនm

Eជាគូអេឡិចត្រុងសេរីនៅលើអាតូមA មានចំនួន n

ឧទាហរណ៍៖

| $BCl_2$ | $AlCl_3$ | $CH_4$ | $NH_3$ | $H_2O$ |
|---|---|---|---|---|
| $AX_2$ | $AX_3$ | $AX_4$ | $AX_3E$ | $AX_2E_2$ |



RUPPDOC

# ២.ធរណីមាត្រនៃម៉ូលេគុលនិងអ៊ីយ៉ុង

## ២.៣.ធរណីមាត្រនៃម៉ូលេគុលឬអ៊ីយ៉ុងតាមវិធី VSEPR

**តារាង១.៣ ទម្រង់ម៉ូលេគុល និងអ៊ីយ៉ុងពីទ្រឹស្តី VSEPR**

| ចំនួនអេឡិចត្រុងលើអាតូមមណ្ឌល | | | រូបមន្តទូទៅ | ទម្រង់ម៉ូលេគុលឬអ៊ីយ៉ុង | ឧទាហរណ៍ |
|---|---|---|---|---|---|
| សម្ព័ន្ធ | មិនសម្ព័ន្ធ | សរុប | | | |
| 2 | 0 | 2 | $AX_2$ | លីនេអ៊ែរ | $BeH_2$ |
| 3 | 0 | 3 | $AX_3$ | ត្រីកោណប្លង់ | $BF_3$ , $^+CH_3$ |
| 4 | 0 | 4 | $AX_4$ | ចតុមុខ | $CH_4$, $^+NH_4$ |
| 3 | 1 | 4 | $AX_3E$ | ពីរ៉ាមីតត្រីកោណ | $NH_3$, $^-CH_3$ |
| 2 | 2 | 4 | $AX_2E_2$ | មុំ ឬបង្កោង | $H_2O$ |

RUPPDOC

# ២.ធរណីមាត្រនៃម៉ូលេគុលនិងអ៊ីយ៉ុង

## ២.៣.ធរណីមាត្រនៃម៉ូលេគុលឬអ៊ីយ៉ុងតាមវិធី VSEPR

| ប្រភេទ | ធរណីមាត្រ | ឧទាហរណ៍ | រូប |
|---|---|---|---|
| $AX_2$ ឬ AXE | បន្ទាត់ ឬ លីនេអ៊ែរ | $BeCl_2$ |  |
| $AX_3$ | ត្រីកោណរាប | $BCl_3$ |  |
| $AX_4$ | ចតុមុខ | $CH_4$ |  |
| $AX_2E$ ឬ $AX_2E_2$ | បង្កោង ឬអក្សរV | $H_2O$ |  |
| $AX_3E$ | ពីរ៉ាមីត | $NH_3$ |  |
| $AX_2E_3$ | បន្ទាត់ ឬលីនេអ៊ែរ | $XeF_2$ |  |



RUPPDOC

# ២.ធរណីមាត្រនៃម៉ូលេគុលនិងអ៊ីយ៉ុង

## ២.៣.ធរណីមាត្រនៃម៉ូលេគុលឬអ៊ីយ៉ុងតាមវិធី VSEPR

| | | | |
|---|---|---|---|
| $AX_2E_3$ | បន្ទាត់ ឬលីនេអ៊ែរ | $XeF_2$ |  |
| $AX_5$ | ពីរ៉ាមីត (ឆមុខ) | $PCl_5$ |  |
| $AX_5E$ | ពីរ៉ាមីតបាតជាការេ | $BrF_5$ |  |
| $AX_6$ | អដ្ឋមុខ | $SF_6$ |  |
| $AX_4E$ | ទោងថ្លឹង | $SF_4$ |  |
| $AX_4E_2$ | ការ៉េ | $XeF_4$ |  |
| $AX_3E_2$ | អក្សរT | $SO_3$ |  |

RUPPDOC

# លំហាត់គំរូទី១

អេតាណុលមានរូបមន្ត $CH_3OH$។

ក.សរសេរទម្រង់ឡឺវីសរបស់វា។

ខ.បើCជាអាតូមកណ្ដាល ចូរកំណត់ប្រភេទ និងធរណីមាត្ររបស់វាតាមវិធី VSEPR។

គ.បើOជាអាតូមកណ្ដាល ចូរកំណត់ប្រភេទ និងធរណីមាត្ររបស់វាតាមវិធី VSEPR។



RUPPDOC

# ដំណោះស្រាយ

# លំហាត់គំរូទី២

គេមានអ៊ីយ៉ុង $SO_4^{2-}$។

ក.ចូរឱ្យគំនូសតាងឡឺវីសនៃអាតូមS និង O។

ខ.តើមានទ្វេតាអេឡិចត្រុងប៉ុន្មាននៅក្នុង $SO_4^{2-}$ ។

គ.ចូរឱ្យទម្រង់ឡឺវីសនៃ $SO_4^{2-}$ ព្រមទាំងបញ្ជាក់បន្ទុកជាក់លាក់ផង។

ឃ.ចូរឱ្យធរណីមាត្រនៃអ៊ីយ៉ុង $SO_4^{2-}$ ។



# ដំណោះស្រាយ

# មេរៀនទី២

# រូបសណ្ឋាន និងទ្រង់ទ្រាយម៉ូលេគុល



## វត្ថុបំណង

ក្នុងមេរៀននេះយើងនឹងសិក្សាអំពី៖

- អ៊ីសូមែរប្លង់ និងអ៊ីសូមែលំហ
- អ៊ីសូមែទ្រង់ទ្រាយ និងទ្រង់ទ្រាយពិសេសនៃម៉ូលេគុល

# ១.អ៊ីសូមែ

- អ៊ីសូមែ គឺជាសមាសធាតុទាំងឡាយណាដែលមានរូបមន្តដុលដូចគ្នាតែមានទម្រង់ខុសគ្នា។
- សមាសធាតុអ៊ីសូមែទាំងឡាយមិនត្រួតស៊ីគ្នាមានលក្ខណៈរូប និង លក្ខណៈគីមីខុសគ្នា។
- អ៊ីសូមែមានពីរប្រភេទធំៗគឺ អ៊ីសូមែប្លង់ និងអ៊ីសូមែលំហ។

- ឧទាហរណ៍៖



អាសេតូនប្រើជាថ្នាំលាងក្រចក



ប្រពីឡែនអុកស៊ីតប្រើក្នុងអាហារ



# ២.អ៊ីសូមែប្លង់

- អ៊ីសូមែប្លង់ គឺជាសមាសធាតុទាំងឡាយណាដែលមានរូបមន្តដុលដូចគ្នា តែរូបមន្តលាត ឬរូបមន្ត ស្ទើរលាតខុសគ្នា។
- រូបមន្តលាត ឬរូបមន្តស្ទើរលាត គេហៅថារូបមន្តប្លង់។
- រូបមន្តប្លង់: ការបន្តនៃអាតូមទាំងឡាយនៅក្នុងប្លង់តែមួយ ដោយមិនបញ្ជាក់ពីទីតាំងអាតូមក្នុងលំហទេ។
- អ៊ីសូមែប្លង់មានបីគឺ អ៊ីសូមែខ្សែកាបូន អ៊ីសូមែទីតាំង និងអ៊ីសូមែនាទី។

# ២.អ៊ីសូមែប្លង់

## ២.១ អ៊ីសូមែខ្សែកាបូន

- អ៊ីសូមែខ្សែកាបូន ជាប្រភេទម៉ូលេគុលដែលមានរូបមន្តម៉ូលេគុលដូចគ្នា ខុសគ្នាដោយការបន្តនៃអាតូមកាបូន។
- ឧទាហរណ៍: ប៉ង់តាន $C_5H_{12}$

$CH_3-CH_2-CH_2-CH_2-CH_3$

n–ប៉ង់តាន



អ៊ីសូប៉ង់តាន



ណេអូប៉ង់តាន

- អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើរលាត និងហៅឈ្មោះអ៊ីសូមែរទាំងអស់របស់ $C_6H_{14}$



# ២.អ៊ីសូមែប្លង់

## ២.២ អ៊ីសូមែនាទី

- អ៊ីសូមែនាទី ជាប្រភេទម៉ូលេគុលដែលមានរូបមន្តម៉ូលេគុលដូចគ្នា ខុសគ្នាតែបង្គុំនាទី
- ឧទាហរណ៍: អ៊ីសូមែនៃរូបមន្ត: ($C_3H_8O$)

$CH_3-CH_2-OH$ — អេទីលអាល់កុល

$CH_3-O-CH_3$ — ឌីមេទីលអេទែ

# ២.អ៊ីសូមែប្លង់

## ២.៣ អ៊ីសូមែទីតាំង

- អ៊ីសូមែទីតាំង ជាប្រភេទម៉ូលេគុលដែលមានរូបមន្តម៉ូលេគុលដូចគ្នា ខុសគ្នាតែទីតាំងក្រុមជួស ឬបង្គុំនាទី។

- ឧទាហរណ៍: $CH_2=CH-CH_2-CH_3$ ប៊ុយ–1–អែន  $CH_3-CH=CH-CH_3$ ប៊ុយ–2–អែន

$CH_2(OH)-CH_2-CH_3$ ប្រូប៉ាន–1–អុល  $CH_3-CH(OH)-CH_3$ ប្រូប៉ាន–1–អុល



# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.១ អ៊ីសូមែលំហ

- អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ ជាសមាសធាតុទាំងឡាយណាដែលមានរូបមន្តប្លង់ដូចគ្នាប៉ុន្តែមានរូបមន្តលំហខុសគ្នា។ ម៉ូលេគុលទាំងនោះមិនត្រួតស៊ីគ្នាទេ។
- រូបមន្តលំហ: រូបមន្តដែលបង្ហាញទីតាំងអាតូមក្នុងលំហ។ ដើម្បីតាងទម្រង់ម៉ូលេគុលក្នុងលំហ ដោយប្រើគំរូម៉ូលេគុល ឬប្រើគំនូសតាង។
- ឧទាហរណ៍:




- អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែមានពីរប្រភេទ:

1. អ៊ីសូមែទ្រង់ទ្រាយ ឬអ៊ីសូមែកុងផរម៉ាស្យុង
2. អ៊ីសូមែរូបសណ្ឋាន ឬអ៊ីសូមែកុងភីគួរ៉ាស្យុង

# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.២ អ៊ីសូមែទ្រង់ទ្រាយ

- អ៊ីសូមែទ្រង់ទ្រាយនៃម៉ូលេគុលមួយកើតឡើងដោយរង្វិលជុំវិញសម្ព័ន្ធទោលC-C
- ចំណោលញ៉ូម៉ាន់ជាចំណោលដែលឲ្យក្រោមបង្ហាញពីទ្រង់ទ្រាយម៉ូលេគុលមួយដែលក្នុងនោះភ្នែករបស់អ្នក ត្រូវសង្កេតមើលតាមបណ្តោយសម្ព័ន្ធទោលC-C។
- កាបូននៅខាងមុខគាងដោយចំណុចផ្ចិត និងកាបូននៅខាងក្រោយត្រូវបានគាងដោយរង្វង់។



**ចំណោលញ៉ូម៉ាន**



# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.២ អ៊ីសូមែទ្រង់ទ្រាយ

- សមាសធាតុសរីរាង្គទាំងឡាយមានមុំ $\phi$ ប្រែប្រួល ពី0°ទៅ360° ដូចនេះវាមានទ្រង់ទ្រាយច្រើនរាប់មិនអស់ ដែលកើតឡើងពីរង្វិលជុំវិញសម្ព័ន្ធទោលC-C ក្នុងម៉ូលេគុល។ ក្នុងនោះមានទ្រង់ទ្រាយពិសេសគួរកត់សម្គាល់គឺ:
  - ➢ **ទ្រង់ទ្រាយជាន់** កាលណាមុំ $\phi$ មានតម្លៃ 0° ឬ120° ឬ240°



# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.២ អ៊ីសូមែទ្រង់ទ្រាយ

➢ **ទ្រង់ទ្រាយផ្កាយ** កាលណាមុំ ϕ មានតម្លៃ 60° ឬ180° ឬ360°




➢ **ទ្រង់ទ្រាយបង្ខិត កាលណាមុំϕ មានតម្លៃខុសពីទ្រង់ទ្រាយជាន់និងទ្រង់ទ្រាយផ្កាយ។**









# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

- អ៊ីសូមែរូបសណ្ឋាននៃម៉ូលេគុលដែលមានរូបមន្តប្លង់កំណត់មួយ គឺជាភាពខុសគ្នានៃទីតាំងអាតូមក្នុងលំហ (ដោយមិនគិតពីទីតាំងនៃអាតូម ដែលខុសគ្នាដោយសាររង្វិលជុំវិញសម្ព័ន្ធទោល C-C មួយ ឬច្រើនឡើយ។
- អ៊ីសូមែរូបសណ្ឋានមានពីរប្រភេទគឺ:
  1. អ៊ីសូមែធរណីមាត្រ
  2. អ៊ីសូមែអុបទិច

RUPPDOC

# ៣.អ៊ីសូមែលំហ ឬស្តេរ៉េអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ក. អ៊ីសូមែធរណីមាត្រ(អ៊ីសូមែរូបសណ្ឋាន Z-E)

- អ៊ីសូមែរូបសណ្ឋាន Z-E កើតមានចំពោះសមាសធាតុអេទីលេនិច ឬអាល់សែនដែលមានទម្រង់ (R‑CH=CH‑R') (R និង R' ជាអាតូម ឬក្រុមអាតូមដូចគ្នា) អាតូមH អាចនៅម្ខាង ឬសងខាងសម្ព័ន្ធ ពីរជាន់។



អ៊ីសូមែ(Z) អ៊ីសូមែ(E)



RUPPDOC

# ៣.អ៊ីសូមែលំហ ឬស្តេរ៉េអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ក. អ៊ីសូមែធរណីមាត្រ(អ៊ីសូមែរូបសណ្ឋាន Z-E)

- Z និង E មិនមែនជារូបឆ្លុះគ្នាទៅវិញទៅមកក្នុងកញ្ចក់គេហៅថា **ឌ្យាស្តេរ៉េអូអ៊ីសូមែ** ។
- ឌ្យាស្តេរ៉េអូមែរមានលក្ខណៈរូបដូចជា សីតុណ្ហភាពរំពុះ សីតុណ្ហភាពរលាយ ម៉ាសមាឌរបស់ពួកវាខុសគ្នា។ លក្ខណៈគីមីក៏ខុសគ្នា នេះបណ្តាលមកពីភាពខុសគ្នានៃទីតាំងបណ្តុំអាតូម ឬបង្គុំនាទីក្នុងលំហ។
- ឧទាហរណ៍៖ 2-ប៊ុយតែនមានឌ្យាស្តេរ៉េអូមែរពីរ៖



(Z) (E)

RUPPDOC

# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ក. អ៊ីសូមែធរណីមាត្រ(អ៊ីសូមែរូបសណ្ឋាន Z-E)

- អនុវត្តន៍៖ ចូរគូអ៊ីសូមែ Z-E របស់2-ប៉ង់តែន



RUPPDOC

# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ខ. អ៊ីសូមែអុបទិច ឬគូអេណង់ទ្យូមែ

- អ៊ីសូមែអុបទិច ឬគូអេណង់ទ្យូមែៈ ជាម៉ូលេគុលដែលមានរូបឆ្លុះគ្នាទៅវិញទៅមកក្នុងកញ្ចក់ ប៉ុន្តែមិនត្រួតស៊ីគ្នាទេ។ ករណីនេះបណ្តាលមកពីវត្តមានកាបូនអសុីមេទ្រី។
- កាបូនអសុីមេទ្រីជាអាតូមកាបូនចតុមុខដែលភ្ជាប់ជាមួយអាតូម ឬក្រុមអាតូម៤ខុសៗគ្នា។
- សមាសធាតុមួយមានកាបូនអសុីមេទ្រីសមាសធាតុនោះមានអេណង់ទ្យូមែ។
- ចំនួនអេណង់ទ្យូមែកើនឡើងតាមចំនួនកាបូនអសុីមេទ្រី។ ក្នុងម៉ូលេគុលមួយអាចមានកាបូន អសុីមេទ្រីច្រើន។

RUPPDOC

# ៣.អ៊ីសូមែលំហ ឬស្តេរ៉េអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ខ. អ៊ីសូមែអុបទិច ឬគូអេណង់ទ្យូមែ

- ម៉ូលេគុលមានកាបូនអស៊ីមេទ្រីមួយមានគូអេណង់មែ ជាម៉ូលេគុលគីរ៉ាល់។
- វត្ថុគីរ៉ាល់ គឺជាវត្ថុដែលមិនត្រួតស៊ីគ្នាទៅនឹងរូបភាពរបស់វាក្នុងកញ្ចក់ឆ្លុះ។



វត្ថុអគីរ៉ាល់





វត្ថុគីរ៉ាល់



RUPPDOC

# ៣.អ៊ីសូមែលំហ ឬស្តេរ៉េអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ខ. អ៊ីសូមែអុបទិច ឬគូអេណង់ទ្យូមែ

- ឧទាហរណ៍: កាបូនអស៊ីមេទ្រី: $CH_3$–CHClBr



# ៣.អ៊ីសូមែលំហ ឬស្តេរេអូអ៊ីសូមែ

## ៣.៣ អ៊ីសូមែរូបសណ្ឋាន

### ខ. អ៊ីសូមែអុបទិច ឬគូអេណង់ទ្យូមែ

- អនុវត្តន៍៖ ចូរគូទម្រង់អេណង់ត្យូមែររបស់៖

A. 2-ក្លរ៉ូប៉ិយតាន

2-ប្រូម៉ូបង់តាន



## លំហាត់គំរូទី១

១. ចូរបង្ហាញទម្រង់Z និង E នៃសមាសធាតុស្មើរលាតខាងក្រោម៖

ក.$CH_3-CH=CH-CH_3$

ខ.$CH_3-CH_2-CH=CH-CH_3$

## លំហាត់គំរូទី១

២. ចូរគូសសញ្ញា(*) នៅលើកាបូនអស៊ីមេទ្រីនៃសមាសធាតុស្ទើលាតខាងក្រោម និងគូទម្រង់អេណង់ទ្យូមែរបស់ពួកវា៖

ក.$CH_3$–CHBr–COOH

ខ.$CH_3$–$CH_2$–CHOH–$CH_3$



## លំហាត់គំរូទី២

គេអោយសមាសធាតុសរីរាង្គខាងក្រោម៖




ក. ចូរឱ្យឈ្មោះទម្រង់លំហនីមួយៗខាងលើ។

ខ.ចូរឱ្យរូបមន្តស្ទើរលាតនៃទម្រង់លំហនីមួយៗខាងលើ។

## លំហាត់គំរូទី៣

គេមានសមាសធាតុ A មួយដែលមានរូបមន្តស្ទើរលាត $CH_3$–$CH=CHBr$។

a. ចូរឱ្យឈ្មោះសមាសធាតុAនេះ។

b. តើសមាសធាតុ A នេះមានអ៊ីសូមែររូបសណ្ឋានដែរ ឬទេ? បើមានចូរពន្យល់ និងបញ្ជាក់ប្រភេទអ៊ីសូមែរនោះ។

c. ចូរសរសេរអ៊ីសូមែរដែលអាចមានចំពោះសមាសធាតុ A នេះ។



## លំហាត់គំរូទី៤

គេមានម៉ូលេគុល $C_4H_9Br$។

a. ចូរសរសេរអ៊ីសូមែរប្លង់នៃម៉ូលេគុលនេះ ព្រមទាំងឱ្យឈ្មោះរបស់វា។

b. ចូរលើកឧទាហរណ៍អ៊ីសូមែរទីតាំងក្នុងអ៊ីសូមែរប្លង់ខាងលើមានខ្សែកាបូនទោល។

c. ក្នុងចំណោមអ៊ីសូមែរទាំងអស់ដែលសរសេរបាន តើមួយណាជាម៉ូលេគុលគីរ៉ាល់? ចូរសរសេរអ៊ីសូមែរអុបទិច។

## ដំណោះស្រាយ



## លំហាត់គំរូទី៥

អាល់សែនមួយមានដង់ស៊ីតេធៀបនឹងអ៊ីដ្រូសែនស្មើ 28។

ក. កំណត់រូបមន្តម៉ូលេគុល និងរូបមន្តស្ទើរលាតនៃអ៊ីសូមែរបស់អាល់សែននេះ។

ខ. តើអ៊ីសូមែមួយណាជាអ៊ីសូមែធរណីមាត្រ? ចូរគូរទម្រង់ស្ទើរលាតរបស់ពួកវា។

គ. អ៊ីដ្រាតកម្មអាល់សែនខាងលើគេទទួលបានអាល់កុលA មានកាបូនអាស៊ីមេទ្រីមួយ។ ចូរឱ្យរូបមន្តស្ទើរលាតរបស់អាល់កុលAនេះ។

RUPPDOC

# ដំណោះស្រាយ



RUPPDOC

# ជំពូកទី៣

# អាល់កុល អេទែ

# អាល់ដេអ៊ីត សេតូន

# មេរៀនទី១

## អាល់កុល និងអេទែ



## វត្ថុបំណង



ក្នុងមេរៀននេះយើងនឹងអាចៈ

- ញែកសម្គាល់រវាងអាល់កុល និងអេទែតាមរយៈរូបមន្ត។
- គូរទម្រង់ និងហៅឈ្មោះអាល់កុល និងអេទែ។
- ញែកសម្គាល់ថ្នាក់ទាំងបីរបស់អាល់កុល។
- ពណ៌នាពីលក្ខណៈរូប លក្ខណៈគីមី ទង្វើ និងបម្រើបម្រាស់នៃអាល់កុល អេទែ និងប៉ូលីអាល់កុលមួយចំនួន។

# A. អាល់កុល
3

## ១. និយមន័យ

- អាល់កុល ជាសមាសធាតុសរីរាង្គដែលមានក្រុម (OH) ភ្ជាប់នឹងកាបូនចតុមុខ។




- អាតូមកាបូនដែលភ្ជាប់ដោយក្រុមអ៊ីដ្រុកស៊ីល(OH) ជាអាតូមកាបូនឆ្អែត ដែលជាប់ជាមួយ ក្រុមអាល់សែននីល ឬ អាល់ស៊ីនីល ឬអាតូមកាបូនឆ្អែតដែលភ្ជាប់ជាមួយវង់បង់សែន។












# A. អាល់កុល
3

## ១. និយមន័យ

- សម្គាល់: បើក្រុមអ៊ីដ្រុកស៊ីល(OH) ភ្ជាប់នឹងកាបូនមិនមែនចតុមុខ សមាសធាតុនោះមិនមែនជា អាល់កុលទេ។









RUPPDOC

# A. អាល់កុល
3

## ២.អាល់កុលស្រឡាយអាល់កាន ឬម៉ូណូអាល់កុលឆ្អែត

### ២.១ រូបមន្តទូទៅ

- អាល់កុលស្រឡាយអាល់កានបានមកពីការជំនួសអាតូមអ៊ីដ្រូសែនមួយនៃអាល់កានដោយ ក្រុមអ៊ីដ្រុកស៊ីល(□OH)។
- ម៉ូលេគុលអាល់កុលប្រភេទនេះ មានបង្គុំនាទីអាល់កុលតែមួយ និងមានសម្ព័ន្ធកូវ៉ាឡង់ទោល ទាំងអស់ដូច្នេះគេហៅថា ម៉ូណូអាល់កុលឆ្អែត។
- រូបមន្តទូទៅរបស់ម៉ូណូអាល់កុលឆ្អែតគឺ

$$C_nH_{2n+1}OH \text{ ឬ } C_nH_{2n+2}O \qquad n \geq 1$$



RUPPDOC

# A. អាល់កុល
3

## ២.អាល់កុលស្រឡាយអាល់កាន ឬម៉ូណូអាល់កុលឆ្អែត

### ២.២ នាមវលីអន្តរជាតិ IUPAC

- ការហៅឈ្មោះរបស់អាល់កុលបានមកពីឈ្មោះអាល់កាន និងបន្ថែមបច្ច័មបទ "អុល"
- ឧទាហរណ៍៖
  - $CH_3$-OH — មេតាណុល ឬមេទីលអាល់កុល
  - $CH_3$-$CH_2$ - OH — អេតាណុល ឬអេទីលអាល់កុល
- ការហៅឈ្មោះរបស់អាល់កុលដែលមានកាបូនចាប់ពីបីឡើងទៅ ត្រូវ៖



# A. អាល់កុល 3

## ២.អាល់កុលស្រឡាយអាល់កាន ឬម៉ូណូអាល់កុលឆ្អែត

### ២.២ នាមវលីអន្តរជាតិ IUPAC

- ឧទាហរណ៍៖



ប្រូប៉ាន–1–អុល



ប្រូប៉ាន–2–អុល



ប៊ុយតាន–1–អុល



2–មេទីលប៊ុយតាន–2–អុល



3–មេទីលប៊ុយតាន–2–អុល



# A. អាល់កុល 3

## ២.អាល់កុលស្រឡាយអាល់កាន ឬម៉ូណូអាល់កុលឆ្អែត

### ២.៣ អ៊ីសូមែម៉ូណូអាល់កុលឆ្អែត

- អ៊ីសូមែ ជាសមាសធាតុដែលមានរូបមន្តម៉ូលេគុលដូចគ្នា តែរូបមន្តស្ទើរលាតខុសគ្នា។
- ឧទាហរណ៍៖ សរសេររូបមន្តលាត និងហៅឈ្មោះអ៊ីសូមែទាំងអស់របស់អាល់កុលដែលមានរូបមន្តម៉ូលេគុល $C_5H_{12}O$

RUPPDOC

# A. អាល់កុល
3

## ៣.ថ្នាក់ទាំងបីនៃអាល់កុល

- កាលណាគេភ្ជាប់ក្រុមអ៊ីដ្រុកស៊ីល(?OH) ទៅលើកាបូនតាមថ្នាក់នីមួយៗគេទទួលបានអាល់កុលថ្នាក់នោះ។ R̦▪Ï ƏMЧ ȩ MфыЛ ſ У ȩ Л




- គេចែកថ្នាក់អាល់កុលជាបីថ្នាក់ដោយផ្អែកទៅតាមចំនួនអាតូមកាបូនដែលភ្ជាប់ជាមួយC នាទី ដែលមានទម្រង់ដូចនេះ




ſ У ȩy R̦▪Ï ěþ ſ У ȩy R̦▪Ï ěþI ſ У ȩy R̦▪Ï ěþII



RUPPDOC

# A. អាល់កុល
3

## ៣.ថ្នាក់ទាំងបីនៃអាល់កុល

- ឧទាហរណ៍៖




- អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើរលាត និងកំណត់ថ្នាក់អាល់កុលខាងក្រោម៖
  - អិចសាន-1-អុល
  - 2,2,3-ទ្រីមេទីលប៉ង់តាន-2-អុល
  - 1-ផេនីលប៊ុយតាន-1-អុល
  - 3-អេទីល-2-មេទីលអិចសាន-2-អុល

RUPPDOC

# A. អាល់កុល
3

## ៤. លក្ខណៈរូប

- អាល់កុលបួនតួដំបូងរលាយមិនកំណត់ក្នុងទឹក។ កម្រិតរលាយរបស់អាល់កុលថយចុះជាមួយ នឹងការកើនឡើងនៃចំនួនអាតូមកាបូន។
- អាល់កុលដែលមានកាបូនចាប់ពី១០ ឡើងទៅមិនរលាយក្នុងទឹកទេ។ ចំណុចរំពុះកើនឡើង ជាមួយនឹងការកើនឡើងនៃចំនួនអាតូមកាបូន។






RUPPDOC

# A. អាល់កុល
3

## ៤.លក្ខណៈរូប

តារាង.១.១.លក្ខណៈរូបនៃអាល់កុលមួយចំនួន

| ឈ្មោះអាល់កុល | រូបមន្ត | ចំណុចរលាយ°C | ចំណុចរំពុះ °C | កម្រិតរលាយក្នុងទឹក(g/100mL) |
|---|---|---|---|---|
| មេតាណុល | $CH_3-OH$ | −97 | 64.7 | មិនកំណត់ |
| អេតាណុល | $CH_3-CH_2-OH$ | −117 | 78.3 | មិនកំណត់ |
| ប្រូប៉ាន-1-អុល | $CH_3-CH_2-CH_2-OH$ | −126 | 97.2 | មិនកំណត់ |
| អ៊ីសូប្រូពីលអាល់កុល | $CH_3-CH(CH_3)-OH$ | −88 | 82.3 | មិនកំណត់ |
| ប៊ុយតាន-1-អុល | $CH_3-CH_2-CH_2-CH_2-OH$ | −90 | 117.7 | 8.3 |
| អ៊ីសូប៊ុយទីលអាល់កុល | $CH_3-CH_2(CH_3)-CH_2-OH$ | −108 | 108.0 | 10.0 |
| ស៊ិកប៊ុយទីលអាល់កុល | $CH_3-CH_2-CH_2(CH_3)-OH$ | −114 | 99.0 | 26.0 |
| ទែត្យប៊ុយទីលអាល់កុល | $(CH_3)_3C-OH$ | 25 | 82.5 | មិនកំណត់ |
| អេទីឡែនគ្លីកុល | $HO-CH_2-CH_2-OH$ | −12.6 | 197 | មិនកំណត់ |
| ប្រូពីឡែនគ្លីកុល | $CH_3-CH(OH)-CH_2-OH$ | −59 | 187 | មិនកំណត់ |
| ទ្រីមេទីឡែនគ្លីកុល | $HO-CH_2-CH_2-CH_2-OH$ | −30 | 215 | មិនកំណត់ |
| គ្លីសេរ៉ុល | $HOCH_2-CH(OH)-CH_2OH$ | 18 | 290 | មិនកំណត់ |

RUPPDOC

# A. អាល់កុល
3

## ៥. លក្ខណៈគីមី

- អាល់កុលចូលរួមប្រតិកម្មជាច្រើនដែលកើតឡើងដោយការផ្តាច់សម្ព័ន្ធអុកស៊ីសែនជាមួយ អ៊ីដ្រូសែន( O–H) ឬផ្តាច់សម្ព័ន្ធកាបូន ជាមួយអុកស៊ីសែន(C–OH)។

### ៥.១ រេដុកម្មអាល់កុលដោយសូដ្យូម

- អាល់កុលគ្រប់ថ្នាក់មានប្រតិកម្មជាមួយNa ដោយអាល់កុលរងរេដុកម្មជាអ៊ីយ៉ុងអាល់កូឡាត និងបំភាយឧស្ម័នអ៊ីដ្រូសែន។

Ч Pþ Tó ThčM3ïï PaïBÿ Pã У ëy ш០ C Ч ßÔp

$$2R{-}OH + 2Na \rightarrow 2R{-}ONa + H_2(g)$$

- ឧទាហរណ៍៖
  a. $CH_3\text{-}CH_2\text{-}OH + Na \rightarrow$
  b. $CH_3\text{-}CH_2\text{-}CH_2\text{-}OH + Na \rightarrow$



RUPPDOC

# A. អាល់កុល
3

## ៥. លក្ខណៈគីមី

### ៥.២ ប្រតិកម្មដេស៊ីដ្រាតកម្មអាល់កុល

ĉM3ïï PaßЧ ÿ០ 3Ï Pã У ëy ш០ C BÏ Йëc 1Pțy Лy Op1Pțy Лy ыΠΓ У ëy
¡ ŏ У ÿþ TAl₂O₃ Ч βyЖ ëũ O400°C д ¡ ŏ У ÿþ TH₂SO₄ Ч βyЖ ëũ O180°C

$$R{-}CH_2{-}CH_2{-}OH \rightarrow R{-}CH{=}CH_2 + H_2O$$

- ឧទាហរណ៍៖
  a. $CH_3\text{-}CH_2\text{-}OH \xrightarrow[400^oC]{Al_2O_3}$
  b. $CH_3\text{-}CH_2\text{-}OH \xrightarrow[180^oC]{H_2SO_4}$
  c. $CH_3\text{-}CH_2\text{-}CH_2\text{-}OH \xrightarrow[180^oC]{H_2SO_4}$

RUPPDOC

# A. អាល់កុល 3

## ៥. លក្ខណៈគីមី

### ៥.២ ប្រតិកម្មដេស៊ីដ្រាតកម្មអាល់កុល

- ប្រតិកម្មដេស៊ីដ្រាតកម្មអាល់កុលដោយដកទឹក1ម៉ូលេគុលពី2ម៉ូលេគុលនៃអាល់កុល នៅសីតុណ្ហភាពមិនសូវខ្ពស់គេទទួលបានអេទែ។
- ឧទាហរណ៍៖

$$CH_3{-}CH_2{-}O\boxed{H \;+\; HO}{-}CH_2{-}CH_3 \xrightarrow[250°C]{Al_2O_3}$$

$$CH_3{-}CH_2{-}O\boxed{H \;+\; HO}{-}CH_2{-}CH_3 \xrightarrow[140°C]{H_2SO_4}$$



RUPPDOC

# A. អាល់កុល 3

## ៥. លក្ខណៈគីមី

### ៥.៣ ប្រតិកម្មជាមួយអ៊ីដ្រូសែនអាឡូសែន (HCl HBr…)

ſ У ёу щ̣ӨМЗї Рậ Р҈ ЪӯВӹН ЛГ Щф̣Н Лх(HX)
Мщ̣Т̈●Ŧ Л! ſ У єЂУ ſ Щф̣Н Лх

$$R{-}OH \quad + \quad HX \quad \rightarrow \quad R{-}X \quad + \quad H_2O$$

- ឧទាហរណ៍៖

a. $CH_3\text{-}CH_2\text{-}OH \quad + \quad H - Cl \quad \rightarrow$

b. $CH_3\text{-}CH_2OH\text{-}CH_3 \quad + \quad H - Br \quad \rightarrow$

c. $CH_3\text{-}CH_2\text{-}CH_2\text{-}OH \quad + \quad H - I \quad \rightarrow$

# A. អាល់កុល 3

## ៥. លក្ខណៈគីមី

### ៥.៤ ប្រតិកម្មអុកស៊ីតកម្មអាល់កុល

### ៥.៤.១ ប្រតិកម្មចំហេះ

[illegible]

$$C_nH_{2n+1}OH + \left(\frac{3n}{2}\right) O_2 \rightarrow nCO_2 + (n+1)H_2O$$

- ឧទាហរណ៍៖

a. $CH_3\text{-}CH_2\text{-}OH + O_2 \rightarrow$

b. $CH_3\text{-}CH_2OH\text{-}CH_3 + O_2 \rightarrow$

c. $CH_3\text{-}CH_2\text{-}CH_2\text{-}OH + O_2 \rightarrow$

d. $CH_3\text{-}CH_2\text{-}CH_2\text{-}CH_2\text{-}OH + O_2 \rightarrow$



# A. អាល់កុល 3

## ៥. លក្ខណៈគីមី

### ៥.៤ ប្រតិកម្មអុកស៊ីតកម្មអាល់កុល

### ៥.៤.២ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួលនៃអាល់កុល

[illegible]

[illegible]

$$R\text{–}CH_2\text{–}OH \xrightarrow{[0]} R\text{–}CHO$$

- ឧទាហរណ៍៖អុកស៊ីតកម្មអេតាណុលដោយសូលុយស្យុងប៉ូតាស្យូមឌីក្រូម៉ាត($K_2Cr_2O_7$) មិនគ្រប់គ្រាន់ ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច$H_2SO_4$៖

$$Cr_2O_7^{2-} + 14H^+ + 6e^- \longrightarrow 2Cr^{3+} + 7H_2O$$
$$CH_3-CH_2-OH \longrightarrow CH_3-CHO + 2H^+ + 2e^- \quad \times 3$$

$$3CH_3\text{-}CH_2\text{-}OH + Cr_2O_7^{2-} + 8H^+ \longrightarrow 3CH_3\text{-}CHO + 2Cr^{3+} + 7H_2O$$

# A. អាល់កុល
3

## ៥. លក្ខណៈគីមី

### ៥.៤ ប្រតិកម្មអុកស៊ីតកម្មអាល់កុល

### ៥.៤.២ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួលនៃអាល់កុល

- **ចំណាំ:** គេអាចប្រើសូលុយស្យុង$KMnO_4$ ធ្វើអុកស៊ីតកម្មលើអាល់កុលថ្នាក់I គេទទួលបានអាស៊ីតកាបុកស៊ីលិច។ តែបើគេជ្រើសរើសសូលុយស្យុង $K_2Cr_2O_7$ មកប្រើគឺដើម្បីទទួលបានអាល់ដេអ៊ីត។ មូលហេតុមកពី $MnO_4^-$ ជាអុកស៊ីតករខ្លាំងជាង $Cr_2O_7^{2-}$ ។
  - $E^o(MnO^{4-}/Mn^{2+}) = 1.51V$  $E^o(Cr_2O_7^{2-}/Cr^{3+}) = 1.33V$



# A. អាល់កុល
3

## ៥. លក្ខណៈគីមី

### ៥.៤ ប្រតិកម្មអុកស៊ីតកម្មអាល់កុល

### ៥.៤.២ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួលនៃអាល់កុល

- អុកស៊ីតកម្មអាល់ថ្នាក់II គេទទួលបានសេតូន




- ឧទាហរណ៍៖ អុកស៊ីតកម្មប្រូប៉ាន–2–អុល ដោយសូលុយស្យុងប៉ូតាស្យូមឌីក្រូម៉ាត ($K_2Cr_2O_7$) ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច $H_2SO_4$

$$Cr_2O_7^{2-} + 14H^+ + 6e^- \rightarrow 2Cr^{3+} + 7H_2O$$
$$CH_3–CHOH–CH_3 \rightarrow CH_3–CO–CH_3 + 2H^+ + 2e^- \quad (\times 3)$$

$$3CH_3–CHOH–CH_3 + Cr_2O_7^{2-} + 8H^+ \rightarrow 3CH_3–CO–CH_3 + 2Cr^{3+} + 7H_2O$$

# A. អាល់កុល
3

## ៥. លក្ខណៈគីមី

### ៥.៤ ប្រតិកម្មអុកស៊ីតកម្មអាល់កុល

### ៥.៤.២ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួលនៃអាល់កុល

$$R_1-\underset{\text{អាល់កុលថ្នាក់II}}{CH(OH)}-R_2 \xrightarrow{[O]} R_1-\underset{\text{សេតូន}}{C(=O)}-R_2$$

- ឧទាហរណ៍: អុកស៊ីតកម្មប្រូប៉ាន□-2-□អុល ដោយសូលុយស្យុងប៉ូតាស្យូមឌីក្រូម៉ាត ($K_2Cr_2O_7$) ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច$H_2SO_4$៖

$$Cr_2O_7^{2-} + 14H^+ + 6e^- \longrightarrow 2Cr^{3+} + 7H_2O$$

$$CH_3-CH(OH)-CH_3 \longrightarrow CH_3-C(=O)-CH_3 + 2H^+ + 2e^- \quad \times 3$$

$$3CH_3\text{-}CH(OH)\text{-}CH_3 + Cr_2O_7^{2-} + 8H^+ \longrightarrow 3CH_3-CO-CH_3 + 2Cr^{3+} + 7H_2O$$

- ចំណាំ: ចំពោះអាល់កុលថ្នាក់III មិនរងអុកស៊ីតកម្មទេ។



# A. អាល់កុល
3

## ៥. លក្ខណៈគីមី

### ៥.៥ ប្រតិកម្មដេអ៊ីដ្រូសែនកម្ម

$$\underset{\text{អាល់កុលថ្នាក់I}}{R-CH_2-OH} \xrightarrow{Cu\,/\,t^\circ} \underset{\text{អាល់ដេអ៊ីត}}{R-CHO} + H_2$$

$$\underset{\text{អាល់កុលថ្នាក់II}}{R-CHOH-CH_3} \xrightarrow{Cu\,/\,t^\circ} \underset{\text{សេតូន}}{R-CO-CH_3} + H_2$$

- ឧទាហរណ៍:

$$CH_3-CH_2-OH \xrightarrow{Cu\,/\,300^\circ C}$$

$$CH_3-CHOH-CH_3 \xrightarrow{Cu\,/\,300^\circ C}$$

RUPPDOC

# A. អាល់កុល
# 3

## ៥. លក្ខណៈគីមី

### ៥.៦ ប្រតិកម្មអេស្ទែកម្ម

- ប្រតិកម្មអេស្ទែកម្មជាប្រតិកម្មរវាងអាស៊ីតកាបុកស៊ីលិចជាមួយអាល់កុល ដែលមាន $H_2SO_4$ ជាកាតាលីករ ផលិតផលទទួលបានជាអេស្ទែ៖

$$R_1{-}COOH + R_2{-}OH \rightleftarrows R_1{-}COO{-}R_2 + H_2O$$

អាស៊ីតកាបុកស៊ីលិច អាល់កុល អេស្ទែ

- ឧទាហរណ៍៖

$$CH_3{-}COOH + CH_3{-}OH \rightleftarrows$$

អាស៊ីតអាសេទិច មេតាណុល



RUPPDOC

# A. អាល់កុល
# 3

## ៦. ទង្វើអាល់កុល

### ៦.១ ប្រតិកម្មអ៊ីដ្រាតកម្មអាល់សែន

$$C_nH_{2n} + H_2O \xrightarrow{\text{អាស៊ីត}} C_nH_{2n+1}OH$$

អាល់សែន ទឹក អាល់កុល

- ឧទាហរណ៍៖

$$CH_2{=}CH_2 + H_2O \rightarrow$$

$$CH_2{=}CH{-}CH_3 + H_2O \rightarrow$$



# A. អាល់កុល 3

## ៦. ទង្វើអាល់កុល

### ៦.២ ទង្វើមេតាណុល

- នៅសីតុណ្ហភាពប្រមាណ400°C សម្ពាធ200atm និងមានកាតាលីករ ឧស្សាហកម្មមេតាណុលត្រូវបានទង្វើឡើងតាមរយៈប្រតិកម្ម៖

$$CO + 2H_2 \rightarrow CH_3{-}OH$$

### ៦.៣ ទង្វើអេតាណុល

- គេអាចធ្វើអេតាណុលដោយល្បើងអាល់កុលនៃគ្លុយកូស $C_6H_{12}O_6$

$$C_6H_{12}O_6 \xrightarrow{\text{កាតាលីករ}} 2CH_3{-}CH_2{-}OH + 2CO_2$$

$$2(C_6H_{10}O_5)_n + nH_2O \xrightarrow{\text{អង់ស៊ីម}} n\,C_{12}H_{22}O_{11}$$

$$\underset{\text{ម៉ាល់តូស}}{C_{12}H_{22}O_{11}} + H_2O \xrightarrow{\text{អង់ស៊ីម}} \underset{\text{អេតាណុល}}{4CH_3{-}CH_2{-}OH} + 4CO_2$$



# A. អាល់កុល 3

## ៦. ទង្វើអាល់កុល

### ៦.៤ ប្រតិកម្មអុកស៊ីមែគួរ៉ាស្យូង-ដេមែគួរ៉ាស្យូងលើអាល់សែន

$$C_nH_{2n} \xrightarrow[\text{(2) NaBH}_4\text{,NaOH}]{\text{(1) Hg(OAc)}_2\text{,H}_2\text{O /THF}} C_nH_{2n+1}OH$$

- ឧទាហរណ៍៖

$$CH_2{=}C(CH_3){-}CH_3 \xrightarrow[\text{(2) NaBH}_4\text{,NaOH}]{\text{(1) Hg(OAc)}_2\text{,H}_2\text{O /THF}}$$

RUPPDOC

# A. អាល់កុល 3

## ៦. ទង្វើអាល់កុល

### ៦.៥ អ៊ីដ្រូបរ៉ាស្យុង-អុស៊ីតកម្មលើអាល់សែន

$$C_nH_{2n} \xrightarrow[(2)\ H_2O_2\ ,\ NaOH]{(1)\ BH_3\ /THF} C_nH_{2n+1}OH$$

- ឧទាហរណ៍៖

$$CH_2{=}C(CH_3){-}CH_3 \xrightarrow[(2)\ H_2O_2\ ,\ NaOH]{(1)\ BH_3\ /THF}$$



RUPPDOC

# A. អាល់កុល 3

## ៧. បម្រើបម្រាស់

- មេតាណុល ជាអង្គធាតុរាវថ្លា គ្មានពណ៌ ងាយហើរ ដង់ស៊ីតេ 0.97g/mL ពុះនៅ 64.7°C និងមានក្លិនប្រហាក់ប្រហែលនឹងអេតាណុលដែរ។
- គេប្រើវាសំយោគផលិតផលជាច្រើន ដូចជាផលិតផរម៉ុលសំរាប់រក្សាសពទុកឱ្យបានយូរ និងរក្សាសត្វងាប់កុំឱ្យស្អុយ។
- ក្នុងរោងចក្រកាត់ដេរ គេប្រើមេតាណុលជាធាតុរំលាយសម្រាប់វែនី និងទឹកអប់។
- មេតាណុល មានគ្រោះថ្នាក់ជាទីបំផុតជាពិសេសចំពោះភ្នែក។ ដូចនេះហើយទើបមានកម្មកររោងចក្រពុលសន្លប់ជាញឹកញាប់ដោយសារ មេតាណុល។

RUPPDOC

# A. អាល់កុល
3

## ៧. បម្រើបម្រាស់

- អេតាណុលកកនៅ 114°Cនិង ពុះនៅ 87.3°C វាមានក្លិនឈ្ងុយ រសជាតិក្តៅឈ្ងួលស្រាលជាងទឹក ដង់ស៊ីតេ 0.8g/mL និងរលាយក្នុងទឹកគ្មានកំណត់ ។
- អេតាណុលមានសារៈសំខាន់ក្នុងជីវភាពរស់នៅ គេប្រើអេតាណុលសម្រាប់ធ្វើទឹកអប់ ភេសជ្ជៈទឹកខ្មេះ ប្រើក្នុងវេជ្ជសាស្ត្រ ដូចជាជូតស្បែកមុនពេលចាក់ថ្នាំ លាងមុខរបួស។



RUPPDOC

# A. អាល់កុល
3

## ៨. ប៉ូលីអាល់កុល

- ប៉ូលីអាល់កុល ឬប៉ូលីអុលជាសមាសធាតុសរីរាង្គ ដែលម៉ូលេគុលមានក្រុមអ៊ីដ្រុកស៊ីល ពីរ ឬ ច្រើន ហើយក្រុមនីមួយៗភ្ជាប់ទៅនឹងកាបូនចតុមុខផ្សេងៗគ្នា។
- ប៉ូលីអាល់កុលមានលក្ខណៈគីមីស្រដៀងគ្នាជាមួយនឹងម៉ូណូអាល់កុលដែរ។
- ឧទាហរណ៍៖

| $HO-CH_2-CH_2-OH$ | $HO-CH_2-CHOH-CH_2-OH$ |
| --- | --- |
| អេតាន-1,2-ឌីអុល | ប្រូប៉ាន-1,2,3-ទ្រីអុល ឬ គ្លីសេរ៉ុល |

## A. អាល់កុល 3

### ៨. ប៉ូលីអាល់កុល

### ៨.១ អេតាន-1,2-ឌីអុល ឬគ្លីកុល

#### ៨.១.១ ទង្វើ

- ក្នុងឧស្សាហកម្ម គេធ្វើគ្លីកុលពីអេទីឡែន។ នៅសីតុណ្ហភាព និងសម្ពាធខ្ពស់ គេឱ្យអេទីឡែន ទទួលអុកស៊ីតកម្មដោយអុកស៊ីសែននៃខ្យល់នៅចំពោះមុខកាតាលីករប្រាក់(Ag) គេទទួលបានអេទី ឡែនអុកស៊ីត។ អ៊ីដ្រាតកម្មនៃអេទីឡែនអុកស៊ីតទទួលបានគ្លីកុល៖




គ្លីកុល



## A. អាល់កុល 3

### ៨. ប៉ូលីអាល់កុល

### ៨.១ អេតាន-1,2-ឌីអុល ឬគ្លីកុល

#### ៨.១.២ បម្រើបម្រាស់

- អេតាន-1,2-ឌីអុលជាអង្គធាតុរាវរលាយក្នុងទឹកមិនកំណត់ កកនៅសីតុណ្ហភាព -12°C និងពុះ នៅសីតុណ្ហភាព197°C។ វាជាធាតុរំលាយល្អ។
- គេនិយមប្រើវាជាភ្នាក់ងារប្រឆាំងនឹងកំណកនៅក្នុងរ៉ាឌ្យាទ័រម៉ាស៊ីន។
- គេប្រើគ្លីកុលដើម្បីផលិតផលគ្រឿងផ្ទុះដែលមានឈ្មោះថានីត្រូគ្លីកុល ដោយគ្លីកុលមានអំពើជាមួយអាស៊ីតនីទ្រិច។
- គ្លីកុលក៏ជាវត្ថុធាតុដើម្បីសម្រាប់សំយោគសារធាតុម៉ាក្រូម៉ូលេគុលដែរ។

# A. អាល់កុល 3

## ៨. ប៉ូលីអាល់កុល

### ៨.២ ប្រូប៉ាន-1,2,3-ទ្រីអុល ឬគ្លីសេរ៉ុល ឬគ្លីសេរីន

#### ៨.២.១ ទង្វើ

- គ្លីសេរ៉ុលជាអង្គធាតុរាវគ្មានពណ៌ រសជាតិផ្អែម ពុះនៅសីតុណ្ហភាព290oC រលាយគ្មានកំនត់ ក្នុងទឹក និងក្នុងអាល់កុល។
- ក្នុងឧស្សាហកម្មគេសំយោគគ្លីសេរ៉ុលចេញពីប្រូប៉ែន។






# A. អាល់កុល 3

## ៨. ប៉ូលីអាល់កុល

### ៨.២ ប្រូប៉ាន-1,2,3-ទ្រីអុល ឬគ្លីសេរ៉ុល ឬគ្លីសេរីន

#### ៨.២.១ ទង្វើ

- គេក៏អាចផលិតផលវាតាមប្រព្រឹត្តកម្មលើខ្លាញ់ (ប្រតិកម្មសាប៉ូកម្ម)។






RUPPDOC

# A. អាល់កុល
3

## ៨. ប៉ូលីអាល់កុល

### ៨.២ ប្រូប៉ាន-1,2,3-ទ្រីអុល ឬគ្លីសេរ៉ុល ឬគ្លីសេរីន

#### ៨.២.២ បម្រើបម្រាស់

- គ្លីសេរ៉ុលមានលក្ខណៈស្រូបសំណើមដែររាំងដល់រំហួត គេប្រើវាក្នុងវេជ្ជសាស្ត្រ សម្រាប់ផ្សំ ថ្នាំរឹត ក្នុងគ្រឿងតុបតែងរបស់ស្ត្រី ដូចជាក្រែម សារធាតុសម្រាប់លាបស្បែក សាប៊ូកក់សក់ សាប៊ូដុស ខ្លួន។ល។
- គ្លីសេរីនក៏ត្រូវបានប្រើសម្រាប់ផលិតគ្រឿងផ្ទុះដែលមានឈ្មោះថាទ្រីនីត្រូគ្លីសេរីនដោយ អំពើនៃអាស៊ីតនីទ្រិចលើគ្លីសេរ៉ុលអានីត។



RUPPDOC

# B. អេទែ
3

## ១.និយមន័យ

- អេទែជាសមាសធាតុសរីរាង្គដែលគេចាត់ទុកហាក់ដូចជាស្រឡាយនៃអាល់កុល ដែលអ៊ីដ្រូ សែននៃក្រុម(–OH) ត្រូវបានជំនួសដោយរ៉ាឌីកាល់អ៊ីដ្រូកាបួ។

| R–O–H | R–O–R' |
|---|---|
| អាល់កុល | អេទែ |

- អេទែឆ្អែតមានរូបមន្តទូទៅ $C_nH_{2n+2}O$ ដែល $n \geq 2$

# B. អេទែ

3

## ២.នាមវលី IUPAC

### ២.១ របៀបទី១: នាមវលីដែលបញ្ជាក់ពីនាទីអេទែ

**ហៅឈ្មោះរ៉ាឌីកាល់អ៊ីដ្រូកាបូនីមួយៗតាមលំដាប់អក្ខរក្រមឡាតាំង រួចបន្ថែមពាក្យថា អេទែ**

- ឧទាហរណ៍៖

$CH_3-O-CH_3$ ឌីមេទីលអេទែ

$CH_3-CH_2-O-CH_2-CH_3$ ឌីអេទីលអេទែ

$CH_3-O-CH_2-CH_3$ អេទីលមេទីលអេទែ



មេទីលផេនីលអេទែ



ឌីផេនីលអេទែ



បង់ស៊ីលផេនីលអេទែ



# B. អេទែ

3

## ២.នាមវលី IUPAC

### ២.២ របៀបទី២: នាមវលីតាមអាល់កាន

- យករ៉ាឌីកាល់អ៊ីដ្រូកាបូណាដែលងាយ(ខ្លី) ភ្ជាប់ជាមួយអាតូមអុកស៊ីសែន ក្រុមអាល់កុកស៊ីជា ខ្នែងហើយហៅឈ្មោះថាក្រុមអាល់កុកស៊ី ឬក្រុមអាល់រ៉ុកស៊ី ។

**ទីតាំងខ្នែង + ឈ្មោះខ្នែង + ហៅខ្សែមេ អាល់កាន**

- ឧទាហរណ៍៖

$CH_3-O-CH_3$ មេតុកស៊ីមេតាន

$CH_3-CH_2-O-CH_2-CH_3$ អេតុកស៊ីអេតាន

$CH_3-O-CH_2-CH_3$ មេតុកស៊ីអេតាន



2–អេតុកស៊ីប៊ុយតាន



2–មេតុកស៊ី–3–មេទីលប៊ុយតាន

## B. អេទែ 3

## ២.នាមវលី IUPAC

### ២.២ របៀបទី២: នាមវលីតាមអាល់កាន

- អនុវត្តន៍៖ ចូរហៅឈ្មោះទាំងពីររបៀបរបស់អេទែខាងក្រោម៖

$CH_3–CH_2–CH_2–CH_2–O–CH_3$









## B. អេទែ 3

## ៣.អ៊ីសូមែ

- ឧទាហរណ៍៖ ចូរសរសេររូបមន្តស្ទើរលាត និងហៅឈ្មោះទាំងពីរប្រព័ន្ធរបស់អេទែរ ដែលមានរូបមន្តម៉ូលេគុល៖ $C_5H_{12}O$

## B. អេទែ 3

### ៤.លក្ខណៈរូប

- អេទែជាអង្គធាតុគ្មានពណ៌ មានក្លិនគួរជាទីគាប់ចិត្ត រលាយតិចក្នុងទឹក និងមានសីតុណ្ហភាព រំពុះទាបជាងអាល់កុលដែលមានចំនួនអាតូមកាបូនស្មើគ្នា។
- ឧទាហរណ៍៖

| $CH_3–CH_2–O–CH_2–CH_3$ | $CH_3–CH_2–CH_2–CH_2–OH$ |
|---|---|
| ម៉ាសម៉ូល 74g/mol | ម៉ាសម៉ូល 74g/mol |
| ចំណុចរំពុះ 35°C | ចំណុចរំពុះ 117°C |
| កម្រិតរលាយក្នុងទឹក 7.5g/100mL | កម្រិតរលាយក្នុងទឹក 9g/100mL |

- សីតុណ្ហភាពរំពុះរបស់អាល់កុលគឺបណ្ដាលមកពីសម្ព័ន្ធអ៊ីដ្រូសែនដែលកើតមានរវាងក្រុម (–OH)។ តែអេទែ មិនមានសម្ព័ន្ធអ៊ីដ្រូសែនទេ តែអេទែអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនជាមួយម៉ូលេគុលទឹកបាន។



## B. អេទែ 3

### ៤.លក្ខណៈរូប

- តារាង.១.២.លក្ខណៈរូបនៃអេទែមួយចំនួន

| ឈ្មោះអេទែ | រូបមន្ត | ចំណុចរលាយ°C | ចំណុចរំពុះ °C |
|---|---|---|---|
| ឌីមេទីលអេទែ | $CH_3–O–CH_3$ | –138 | –24.9 |
| អេទីលមេទីលអេទែ | $CH_3–CH_2–O–CH_3$ | –127 | 17.66 |
| ឌីអេទីលអេទែ | $CH_3–CH_2–O–CH_2–CH_3$ | –116 | 34.6 |

RUPPDOC

## B3. អេទែ

### ៥.លក្ខណៈគីមីនៃអេទែ

- អេទែមានប្រតិកម្មជាមួយអ៊ីដ្រូសែនអាឡូសែនលើសក្រោមការដុតកម្តៅ

$$R_1{-}O{-}R_2 + 2H{-}X \xrightarrow{t^o} R_1{-}X + R_2{-}X + H_2O$$

អេទែ អ៊ីដ្រូសែនអាឡូសែន អាល់គីលអាឡូសែន

- ឧទាហរណ៍៖ ដោយការដុតកម្តៅ៖

$CH_3{-}CH_2{-}O{-}CH_3 + HBr \rightarrow$

$CH_3{-}CH_2{-}O{-}CH_2{-}CH_3 + HCl \rightarrow$

$CH_3{-}CH_2{-}O{-}CH_2{-}CH_2{-}CH_3 + HBr \rightarrow$



RUPPDOC

## B3. អេទែ

### ៦.ទង្វើអេទែ

#### ៦.១ ដេស៊ីដ្រាតកម្មអន្តរម៉ូលេគុលអាល់កុល

- ចំពោះអេទែដែលមានរ៉ាឌីកាល់អ៊ីដ្រូកាបួដូចគ្នា(R–O–R)គេអាចធ្វើឡើងតាមប្រតិកម្មដេស៊ីដ្រាតកម្មរវាងពីរម៉ូលេគុលអាល់កុល។

$$R{-}O{-}H + H{-}O{-}R \xrightarrow{HA} R{-}O{-}R + H_2O$$

អាល់កុល អេទែ

- ឧទាហរណ៍៖ ក្នុងកាតាលីករអាស៊ីតស៊ុលផួរិច និងដុតកម្តៅ៖

$CH_3{-}OH + CH_3{-}OH \rightarrow$

$CH_3{-}CH_2{-}OH + CH_3{-}CH_2{-}OH \rightarrow$

$HO{-}CH_2{-}CH_2{-}CH_3 + HO{-}CH_2{-}CH_2{-}CH_3 \rightarrow$

## B. អេទែ
## 3

### ៦.ទង្វើអេទែ

#### ៦.២ វិធីWilliamson

- គេអាចសំយោគអេទែបានចំពោះអេទែ(R–O–R) និង($R_1$–O–$R_2$) ដោយឱ្យអំបិលសូដ្យូមរបស់អាល់កុលមានប្រតិកម្មជាមួយស្រឡាយអាឡូសែន។

$$R_1{-}O{-}Na \quad + \quad R_2{-}X \quad \rightarrow \quad R_1{-}O{-}R_2 \; + \; NaX$$

សូដ្យូមអាល់កុកស៊ីត អាល់គីលអាឡូសែន អេទែ

(X អាចជា: –Br –I $-OSO_2R''$ ឬ $-OSO_2OR''$……..)

- ឧទាហរណ៍៖

$CH_3{-}ONa + CH_3{-}CH_2{-}Br \rightarrow$

$CH_3{-}CH_2{-}ONa + CH_3{-}CH_2{-}I \rightarrow$

$CH_3{-}CH_2{-}CH_2{-}ONa + CH_3{-}OSO_2CH_3 \rightarrow$



## B. អេទែ
## 3

### ៦.ទង្វើអេទែ

#### ៦.៣ ប្រតិកម្មអាល់កុកស៊ីមែគួរ៉ាស្យូង-ដេមែគួរ៉ាស្យូង

- ប្រតិកម្មរវាងអាល់សែនជាមួយអាល់កុលក្នុងវត្តមានអំបិលបារ៉ែត ដូចជាបារ៉ែតអាសេតាត ឬ សំណទ្រីភ្លុយអរ៉ូអាសេតាត។

$$C_nH_{2n} \quad + \quad R{-}OH \xrightarrow[\text{(2) } NaBH_4,\ OH^-]{\text{(1) } Hg(O_2CCF_3)_2} C_nH_{2n+1}{-}O{-}R$$

- ឧទាហរណ៍៖

$$CH_2{=}CH_2 \; + \; CH_3{-}OH \xrightarrow[\text{(2) } NaBH_4,\ OH^-]{\text{(1) } Hg(O_2CCF_3)_2}$$

## B. អេតែ 3

### ៧. បម្រើបម្រាស់

- គេប្រើអេតែជាធាតុរំលាយ វាអាចរំលាយសារធាតុមិនប៉ូលែបាន ដូច្នេះហើយបានជាគេប្រើ វាជាធាតុរំលាយក្នុងប្រតិកម្មអង្គធាតុសរីរាង្គ។



## លំហាត់គំរូទី១ 3

ចូរសរសេរទម្រង់ស្ទើរលាតនៃសមាសធាតុខាងក្រោម:

ក.ប៉ុយ–2–អែន–1–អុល

ខ.ប៉ុយតាន–1,2,4–ទ្រីអុល

គ.ស៊ីលក្លូប៉ង់តាន–1,2–ឌីអុល

ឃ.1–អេទីលស៊ីក្លូប៉ុយតាណុល

ង.2–ក្លរ៉ូអ៊ិច–3–អ៊ីន–1–អុល

ច.តេត្រាអ៊ីដ្រូផរ៉ាន

ឆ.2–អេតុកស៊ីប៉ង់តាន

ជ.អេទីលផេនីលអេតែ

RUPPDOC

## លំហាត់គំរូទី២

3

ចូរសរសេរសមីការបំលែងខាងក្រោមដើម្បីទទួលបានផលិតផលពីA ដល់D






RUPPDOC

## លំហាត់គំរូទី៣

3

វិភាគម៉ូណូអាល់កុលឆ្អែត A មាន O=21.62% គិតជាម៉ាស។

ក.កំណត់រូបមន្តម៉ូលេគុលនៃ A បើម៉ាសម៉ូល A ស្មើ 60g/mol។

ខ.សរសេរអ៊ីសូមែនៃ A និងឱ្យឈ្មោះ។

# ដំណោះស្រាយ

3



# លំហាត់គំរូទី៤

3

គេមានម៉ូលេគុលអាល់កុលឆ្អែតពីរ ដែលមានម៉ាសម៉ូលរៀងគ្នា 46g/mol និង 60g/mol។ គេឱ្យ 5g នៃល្បាយអាល់កុលនេះមានអំពើជាមួយ Na គេទទួលបានឧស្ម័នអ៊ីដ្រូសែន1.12L នៅលក្ខខណ្ឌធម្មតា។

ក.កំណត់រូបមន្តម៉ូលេគុលអាល់កុលនីមួយៗ។

ខ.គណនាម៉ាសអាល់កុលនីមួយៗក្នុងល្បាយដើម។

គ.គណនាសមាសភាពភាគរយជាម៉ាសនៃល្បាយដើម។

RUPPDOC

# ដំណោះស្រាយ

3



RUPPDOC

# ដំណោះស្រាយ

3

# មេរៀនទី២

# អាល់ដេអ៊ីត និងសេតូន



## វត្ថុបំណង

### ក្នុងមេរៀននេះយើងនឹងអាច៖

- ញែកសម្គាល់រវាង អាល់ដេអ៊ីត និងសេតូនតាមរយៈរូបមន្ត។
- សរសេរ និងហៅឈ្មោះអាល់ដេអ៊ីត និងសេតូនមួយចំនួន។
- ពណ៌នាលក្ខណៈរូប និងលក្ខណៈគីមីរបស់អាល់ដេអ៊ីត និងសេតូន។
- ញែកសម្គាល់អាល់ដេអ៊ីតឬសេតូនតាមរយៈអត្តសញ្ញាណកម្ម។

RUPPDOC

# A. អាល់ដេអ៊ីត

## ១. និយមន័យ

- អាល់ដេអ៊ីត ជាសមាសធាតុសរីរាង្គដែលម៉ូលេគុលរបស់វាមានបង្គុំកាបូនីល( $-\overset{O}{\overset{\|}{C}}-$ )ចងសម្ព័ន្ធទៅនឹងអាតូមអ៊ីដ្រូសែនមួយ និងរ៉ាឌីកាល់អ៊ីដ្រូកាបួមួយ ឬអាតូមអ៊ីដ្រូសែនទាំងពីរ។

- អាល់ដេអ៊ីតមានទម្រង់ទូទៅ  ឬ R–CHO

- អាល់ដេអ៊ីតមានរូបមន្តទូទៅ $C_nH_{2n}O$ ដែល ( $n\geq1$ )មានម៉ាសម៉ូល M = (14n + 16) g/mol។



RUPPDOC

# A. អាល់ដេអ៊ីត

## ២.នាមវលី IUPAC

- របៀបហៅឈ្មោះអាល់ដេអ៊ីត




- ឧទាហរណ៍៖



RUPPDOC

# A. អាល់ដេអ៊ីត

## ៣.អ៊ីសូមែ

- អាល់ដេអ៊ីតមានរូបមន្តទូទៅ $C_nH_{2n}O$ ដែល ( $n \geq 1$ )
- ឧទាហរណ៍៖ អាល់ដេអ៊ីតមានកាបូន៤

- ឧទាហរណ៍៖ អាល់ដេអ៊ីតមានកាបូន៥



RUPPDOC

# A. អាល់ដេអ៊ីត

## ៣.អ៊ីសូមែ

- អនុវត្តន៍៖ ចូរសរសេររូបមន្តស្នើរលាត និងហៅឈ្មោះអ៊ីសូមែទាំងអស់របស់អាល់ដេអ៊ីត ដែលមានរូបមន្តម៉ូលេគុល$C_6H_{12}O$ ព្រមទាំងបញ្ជាក់ពីទំនាក់ទំនងអ៊ីសូមែររបស់ពួកវា។

# A. អាល់ដេអ៊ីត

## ៤. លក្ខណៈរូបនៃអាល់ដេអ៊ីត

- អាល់ដេអ៊ីតធ្មេត មេតាណាល់ និងអេតាណាល់ គឺជាឧស្ម័ននៅសីតុណ្ហភាពប្រក្រតី។
- អាល់ដេអ៊ីតមានចំណុចរំពុះទាបជាងអាល់កុលដែលមានម៉ាសម៉ូលប្រហាក់ប្រហែលគ្នា ព្រោះវាគ្មានសម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុល ដែលនាំឱ្យកម្លាំងទំនាញម៉ូលេគុលមិនសូវខ្លាំងដូចអាល់កុល។

| សមាសធាតុ | ឈ្មោះ | ម៉ាសម៉ូល | ចំណុចរំពុះ |
|---|---|---|---|
| $CH_3–CH_2–CH_2–CH_3$ | n–ប៊ុយតាន | 58g/mol | – 0.5°C |
| $CH_3–CH_2–CHO$ | ប្រូប៉ាណាល់ | 58g/mol | 49°C |
| $CH_3–CO–CH_3$ | អាសេតូន | 58g/mol | 56.1°C |
| $CH_3–CH_2–CH_2–OH$ | ប្រូប៉ាន–1–អុល | 60g/mol | 97.2°C |



# A. អាល់ដេអ៊ីត

## ៤. លក្ខណៈរូបនៃអាល់ដេអ៊ីត

- អាល់ដេអ៊ីតមានក្លិនឈ្ងួលខ្លាំង។ មេតាណាល់ ជាឧស្ម័នមួយពុលមានក្លិនឈ្ងួល និងអាចធ្វើឱ្យហៀរទឹកភ្នែក។ តែអាល់ដេអ៊ីតដែលមានអាតូមកាបូនច្រើនមានក្លិនគួរជាទីគាប់ចិត្ត។

| រូបមន្ត | ឈ្មោះ | ចំណុចរលាយ | ចំណុចរំពុះ | ក្នុងទឹក |
|---|---|---|---|---|
| HCHO | ផរម៉ាល់ដេអ៊ីត | –92°C | –21°C | រលាយខ្លាំង |
| $CH_3CHO$ | អាសេតាល់ដេអ៊ីត | –125°C | 21°C | មិនកំណត់ |
| $CH_3CH_2CHO$ | ប្រូប៉ាណាល់ | –81°C | 49°C | រលាយខ្លាំង |
| $CH_3(CH_2)_2CHO$ | ប៊ុយតាណាល់ | –99°C | 76°C | រលាយ |
| $CH_3(CH_2)_3CHO$ | ប៉ង់តាណាល់ | –92°C | 102°C | រលាយតិច |
| $CH_3(CH_2)_4CHO$ | អ៊ិចសាណាល់ | –51°C | 131°C | រលាយតិច |
| $C_6H_5CHO$ | បង់សាល់ដេអ៊ីត | –26°C | 178°C | រលាយតិច |
| $C_6H_5CH_2CHO$ | ផេនីលអាសេតាល់ដេអ៊ីត | 33 | 193°C | រលាយតិច |

RUPPDOC

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.១ ប្រតិកម្មបូកជាមួយអ៊ីដ្រូសែន

- អាល់ដេអ៊ីតមានប្រតិកម្មបូកជាមួយអ៊ីដ្រូសែន នៅសីតុណ្ហភាពខ្ពស់ នៅចំពោះមុខកាតាលីករនីកែល ទទួលបានអាល់កុលថ្នាក់I ។

$$R\text{–}CHO + H_2 \xrightarrow{Ni\,/\,t^{\uparrow}} R\text{–}CH_2\text{–}OH$$

អាល់ដេអ៊ីត → អាល់កុលថ្នាក់I

- ឧទាហរណ៍៖

$$CH_3\text{–}CHO + H_2 \xrightarrow{Ni\,/\,t^{\uparrow}}$$



RUPPDOC

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.២ ប្រតិកម្មបូកជាមួយទឹក

- អាល់ដេអ៊ីតធ្វើប្រតិកម្មជាមួយទឹកឱ្យផលជាអាល់ដេអ៊ីតអ៊ីដ្រាត ។ អាល់ដេអ៊ីតអ៊ីដ្រាតជាសមាសធាតុមិនស៊ប់ វាងាយបំបែកទៅជាទឹក និងអាល់ដេអ៊ីតវិញ។

$$R\text{–}CHO + H_2O \rightleftarrows R\text{–}CH(OH)_2$$

អាល់ដេអ៊ីត → អាល់ដេអ៊ីតអ៊ីដ្រាត

- ឧទាហរណ៍៖

$$H\text{–}CHO + H_2O \rightarrow$$

RUPPDOC

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៣ ប្រតិកម្មអុកស៊ីតកម្មតាមសម្រួល

- អាល់ដេអ៊ីតរងអុកស៊ីតកម្មតាមសម្រួលដោយ ប៉ូតាស្យូមប៊ីក្រូម៉ាត ឬប៉ូតាស្យូមពែម៉ង់កាណាត ក្នុងមជ្ឈដ្ឋានអាស៊ីត ផលិតផលទទួលបានជាអាស៊ីតកាបុកស៊ីលិច។

$$\text{R–CHO} \xrightarrow{[O]} \text{R–COOH}$$

អាល់ដេអ៊ីត → អាស៊ីតកាបុកស៊ីលិច

- ឧទាហរណ៍៖

$$CH_3\text{–}CHO \xrightarrow{[O]}$$



RUPPDOC

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៤ ប្រតិកម្មជាមួយ 2,4-DNPH

- 2,4-DNPH គេប្រើសម្រាប់អត្តសញ្ញាណកម្មបង្គុំកាបូនីល ពេលគេបន្តក់ចូលប៉ះជាមួយសូលុយស្យុង អាល់ដេអ៊ីត ឬ សេតូន ឱ្យកករពណ៌លឿងចាស់។



អាល់ដេអ៊ីត ឬ សេតូន  2,4–ឌីនីត្រូផេនីលអ៊ីដ្រាស៊ីន  2,4–ឌីនីត្រូផេនីលអ៊ីដ្រាសូន

កករពណ៌លឿងចាស់

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៥ អុកស៊ីតកម្មអាល់ដេអ៊ីតដោយរ៉េអាក់ទីបតូឡង់ ( កុំផ្លិច $Ag^+$ )

- រ៉េអាក់ទីបតូឡង់ ជាសូលុយស្យុងថ្លា គ្មានពណ៌បានមកពីការបន្តក់សូលុយស្យុងអាម៉ូញ៉ាក់ទៅក្នុងសូលុយស្យុងប្រាក់នីត្រាត បង្កើតបានជា$[Ag(NH_3)_2]^+$ អ៊ីយ៉ុងឌីអាមីនប្រាក់។

$$R\text{–}CHO + 3OH^- \rightarrow R\text{–}COO^- + 2H_2O + 2e^-$$
$$[Ag(NH_3)_2]^+ + 1e^- \rightarrow Ag\,(s) + 2NH_3 \quad (\times 2)$$
$$R\text{–}CHO + 2[Ag(NH_3)_2]^+ + 3OH^- \rightarrow R\text{–}COO^- + 4NH_3 + 2Ag\,(s) + 2H_2O$$

- ចំណាំ: គេប្រើរ៉េអាក់ទីបតូឡង់ដើម្បី រកវត្តមានអាល់ដេអ៊ីត។

13

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៦ អុកស៊ីតកម្មអាល់ដេអ៊ីតដោយទឹកផេលិញ ( កុំផ្លិច $Cu^{2+}$ )

- ទឹកផេលិញ គឺជាសូលុយស្យុងបាសមានពណ៌ខៀវចាស់ ដែលក្នុងនោះមានកុំផ្លិច ដែលកើតឡើងដោយ $Cu^{2+}$ ជាមួយអាញ៉ុងនៃអាស៊ីត តាកទ្រិច។ ផលិតផលដែលទទួលបាន អាញ៉ុងកាបុកស៊ីឡាត និងកករ $Cu_2O$ ពណ៌ក្រហមឥដ្ឋ។

$$R\text{–}CHO + 3OH^- \rightarrow R\text{–}COO^- + 2H_2O + 2e^-$$
$$2Cu^{2+} + 2OH^- + 2e^- \rightarrow Cu_2O\,(s) + H_2O$$
$$R\text{–}CHO + 2Cu^{2+} + 5OH^- \rightarrow R\text{–}COO^- + Cu_2O + 3H_2O$$

14

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៧ ប្រតិកម្មជាមួយអាល់កុល

- អាល់ដេអ៊ីតមានប្រតិកម្មជាមួយអាល់កុល បង្កើតបាន ទម្រង់អេមីអាសេតាល់។ ទម្រង់អេមីអាសេតាល់ជាទម្រង់មួយដែលមានក្រុម (–OH ) និងក្រុម (–OR) ជួសនៅលើអាតូមកាបូនតែមួយ។




- ឧទាហរណ៍៖ ប្រតិកម្មរវាងអាសេតាល់ដេអ៊ីតជាមួយមេតាណុល



15

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៧ ប្រតិកម្មជាមួយអាល់កុល

- អាល់ដេអ៊ីតមានប្រតិកម្មជាមួយអាល់កុលដោយមានបន្ថែមឧស្ម័នអ៊ីដ្រូសែនក្លរួ បង្កើតបាន ទម្រង់ អាសេតាល់។ ទម្រង់អាសេតាល់ ជាទម្រង់មួយដែលមានក្រុម (–OR) ពីរ ជួសនៅលើអាតូមកាបូនតែមួយ។




- ឧទាហរណ៍៖ប្រតិកម្មរវាងអាសេតាល់ជាមួយមេតាណុល




16

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៨ ប្រតិកម្មជាមួយស្រឡាយអាម៉ូញ៉ាក់

$$R_1-\overset{\overset{\displaystyle O}{\|}}{C}-H \quad + \quad H_2N-Z \quad \rightleftarrows \quad R_1-\overset{\overset{\displaystyle Z-N}{\|}}{C}-H \quad + \quad H_2O$$

អាល់ដេអ៊ីត ស្រឡាយអាម៉ូញ៉ាក់ ផលិតផល

| ស្រឡាយអាម៉ូញ៉ាក់ H₂N–Z | ផលិតផលទទួលបាន |
|---|---|
| $H_2N-H$ អាម៉ូញ៉ាក់ | អ៊ីមីន |
| $H_2N-R$ អាមីនថ្នាក់I | អ៊ីមីន |
| $H_2N-OH$ អ៊ីដ្រុកស៊ីលឡាមីន | អុកស៊ីម |
| $H_2N-NH_2$ អ៊ីដ្រាស៊ីន | អ៊ីដ្រាសូន |
| $H_2N-NH-C_6H_5$ ផេនីលអ៊ីដ្រាស៊ីន | ផេនីអ៊ីដ្រាសូន |
| $H_2N-NH-CO-NH_2$ សេមីកាបាស៊ីត | សេមីកាបាសូន |



# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៩ ប្រតិកម្មជាមួយស្រឡាយអាម៉ូញ៉ាក់( អាមីនថ្នាក់II )

- អាល់ដេអ៊ីតមានប្រតិកម្មជាមួយ អាមីនថ្នាក់ទីII ផលិតផលជា អេណាមីន (Enamine)។ អេណាមីន ជាសមាសធាតុមិនទាន់ឆ្អែត ដែលកើតឡើងនៅពេលដែលអាល់ដេអ៊ីត ឬ សេតូន មានប្រតិកម្មជាមួយអាមីនថ្នាក់ទីII។ ផលិតផលមានទម្រង់ជាអាល់សែន និងអាមីន។

$$R_1-CH_2-\overset{\overset{\displaystyle O}{\|}}{C}-R_2 \quad + \quad \underset{\underset{\displaystyle R_3}{|}}{HN}-R_4 \quad \rightarrow \quad R_1-CH=\underset{\underset{\displaystyle R_2}{|}}{C}-\underset{\underset{\displaystyle R_3}{|}}{N}-R_4 \quad + \quad H_2O$$

អាល់ដេអ៊ីត ឬសេតូន អាមីនថ្នាក់ទីII អេណាមីន

- ឧទាហរណ៍៖ប្រតិកម្មរវាង ប៊ុយតាណាល់ជាមួយឌីមេទីលឡាមីនៈ

$$H_3C-CH_2-\overset{\overset{\displaystyle O}{\|}}{C}-H \quad + \quad \underset{\underset{\displaystyle CH_3}{|}}{HN}-CH_3 \quad \rightarrow \quad H_3C-CH=\underset{\underset{\displaystyle H}{|}}{C}-\underset{\underset{\displaystyle CH_3}{|}}{N}-CH_3 \quad + \quad H_2O$$

# A. អាល់ដេអ៊ីត

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.១០ ប្រតិកម្មជាមួយអ៊ីដ្រូសែនស្យានួ

- អ៊ីដ្រូសែនស្យានួ មានប្រតិកម្មទៅលើបង្គុំកាបូនីល របស់អាល់ដេអ៊ីត ឬសេតូន ផលិតផលទទួលបានជា ស្យាណូអ៊ីឌ្រីន (Cyanohydrin)។

$$R_1-\overset{\overset{\displaystyle O}{\|}}{C}-R_2 \;+\; HC\equiv N \;\rightleftarrows\; R_1-\underset{\underset{\displaystyle R_2}{|}}{\overset{\overset{\displaystyle OH}{|}}{C}}-C\equiv N$$

អាល់ដេអ៊ីត ឬសេតូន | អ៊ីដ្រូសែនស្យានួ | ស្យាណូអ៊ីឌ្រីន

- ឧទាហរណ៍៖ប្រតិកម្មរវាងអេតាណាល់ជាមួយអ៊ីដ្រូសែនស្យានួៈ

$$H_3C-\overset{\overset{\displaystyle O}{\|}}{C}-H \;+\; HC\equiv N \;\rightleftarrows\; H_3C-\underset{\underset{\displaystyle H}{|}}{\overset{\overset{\displaystyle OH}{|}}{C}}-C\equiv N$$



# A. អាល់ដេអ៊ីត

## ៦. ទទួលអាល់ដេអ៊ីត

### ៦.១ អុកស៊ីតកម្មអ៊ីដ្រូកាបួ

- នៅក្នុងលក្ខខណ្ឌសមស្របអ៊ីដ្រូកាបួប្រភេទខ្លះរងអុកស៊ីតកម្មក្លាយជាអាល់ដេអ៊ីតៈ

$$R{-}CH_3 + O_2 \xrightarrow{t^\circ} R{-}CHO + H_2O$$

អាល់កាន | អាល់ដេអ៊ីត

- ឧទាហរណ៍៖

$$CH_4 + O_2 \xrightarrow{600^\circ C-700^\circ C}$$

# A. អាល់ដេអ៊ីត

## ៦. ទង្វើអាល់ដេអ៊ីត

### ៦.២ អ៊ីដ្រាតកម្មអាល់ស៊ីនជួសមួយ

- ក្នុងមជ្ឈដ្ឋានអាស៊ីត $H_2SO_4$រាវ និងវត្តមាន $Hg^{2+}$ អាល់ស៊ីនរងអ៊ីដ្រាតកម្មជាអាល់ដេអ៊ីត:

$$\text{R–C}\equiv\text{CH} + H_2O \xrightarrow{Hg^{2+}/H_2SO_4} \text{R–CHO}$$

អាល់ស៊ីន → អាល់ដេអ៊ីត

- ឧទាហរណ៍៖

$$\text{CH}\equiv\text{CH} + H_2O \xrightarrow{Hg^{2+}/H_2SO_4}$$

21

# A. អាល់ដេអ៊ីត

## ៦. ទង្វើអាល់ដេអ៊ីត

### ៦.៣ អុកស៊ីតកម្មអាល់កុលថ្នាក់ I

- អុកស៊ីតកម្មអាល់កុលថ្នាក់ I ផលិតផលទទួលបានជាអាល់ដេអ៊ីត:

$$\text{R–CH}_2\text{–OH} \xrightarrow{[O]} \text{R–CHO}$$

អាល់កុលថ្នាក់I → អាល់ដេអ៊ីត

- ឧទាហរណ៍៖ អុកស៊ីតកម្មអេតាណុល ($CH_3–CH_2–OH$) ដោយសូលុយស្យុងប៉ូតាស្យូមឌីក្រូម៉ាត ($K_2Cr_2O_7$) មិនគ្រប់គ្រាន់ ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច $H_2SO_4$ :

$$CH_3–CH_2–OH \xrightarrow{Cr_2O_7^{2-}/\,H_2SO_4}$$

22

RUPPDOC

# A. អាល់ដេអ៊ីត

## ៦. ទង្វើអាល់ដេអ៊ីត

### ៦.៥ អូសូនកម្មអាល់សែន




- ឧទាហរណ៍៖



RUPPDOC

# A. អាល់ដេអ៊ីត

## ៦. ទង្វើអាល់ដេអ៊ីត

### ៦.៥ អូសូនកម្មអាល់សែន




- ឧទាហរណ៍៖

# A. អាល់ដេអ៊ីត

## ៦. ទង្វើអាល់ដេអ៊ីត

### ៦.៦ រេដុកម្ម អាស៊ីលក្លរួ អេស្ទែ និងនីទ្រីល




- ឧទាហរណ៍៖



# A. អាល់ដេអ៊ីត

## ៧. ប្រើប្រាស់



# B. អាសេតូន

## ១. និយមន័យ

- សេតូន ជាសមាសធាតុសរីរាង្គស្រឡាយកាបូនីល ដែលក្នុងនោះសម្ព័ន្ធទាំងពីរ នៃបង្គុំកាបូនីល( $-\overset{O}{\overset{\|}{C}}-$ ) ត្រូវភ្ជាប់ទៅនឹងអាតូមកាបូននៃរ៉ាឌីកាល់អ៊ីដ្រូកាបួពីរទៀត។
- សេតូនមានទម្រង់ទូទៅ $R-\overset{O}{\overset{\|}{C}}-R'$ ឬ R–CO–R'
- R និង R′ ជារ៉ាឌីកាល់អ៊ីដ្រូកាបួ អាចដូចគ្នា អាចជារ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត មិនទាន់ឆ្អែត ស៊ីគ្លិច ឬប្រហើរ។
- សេតូនឆ្អែតមានរូបមន្តទូទៅ$C_nH_{2n}O$ដែល( $n \geq 3$ )មានម៉ាសម៉ូល$M = (14n + 16)$ g/mol។



# B. សេតូន

## ២.នាមវលី IUPAC

**ជ្រើសខ្សែមេ**
- មានបង្គុំនាទីកាបូនីល
- ខ្សែកាបូនវែងជាងគេ
- មានក្រុមជួសច្រើនជាងគេ

**បង់លេខ**
- បង្គុំCO មានលេខតូចបំផុត
- ខ្នែងមានលេខតូចបំផុត

**ហៅឈ្មោះ**
- ទីតាំងខ្នែង + ឈ្មោះខ្នែង + ខ្សែមេអាល់កាន + ទីតាំងCO + អូន

- **ឧទាហរណ៍៖**

$CH_3-CO-CH_3$ $H_3C-CH(CH_3)-CO-CH_2-CH_3$ $CH_3-CO-C(CH_3)_2-CH_3$

RUPPDOC

# B. សេតូន

## ៣.អ៊ីសូមែ

- សេតូនមានកាបូន=5



RUPPDOC

# B. សេតូន

## ៣.អ៊ីសូមែ

- អនុវត្តន៍៖ ចូរសរសេររូបមន្តស្ទើលាត និងហៅឈ្មោះសេតូនទាំងអស់ដែលមានរូបមន្ត ម៉ូលេគុល $C_6H_{12}O$ និងបញ្ជាក់ពីទំនាក់ទំនងអ៊ីសូមែរបស់ពួកវា។

RUPPDOC

# B. សេតូន

## ៤.លក្ខណៈរូបនៃសេតូន

- សេតូនមានសីតុណ្ហភាពរំពុះខ្ពស់ជាអាល់ដេអ៊ីត បណ្តាលមកពីបង្គុំកាបូនីលដែលមានភាពប៉ូលែខ្លាំង ដែលធ្វើឱ្យមានទំនាញអន្តរម៉ូលេគុលខ្លាំងរវាងប៉ូល និងប៉ូល។
- សេតូនមានសីតុណ្ហភាពទាបជាងអាល់កុល ដោយសារបង្គុំកាបូនីលរបស់សេតូន មិនអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុលទេ តែអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនជាមួយ(–OH) នៃទឹក។

| សមាសធាតុ | ឈ្មោះ | ម៉ាសម៉ូល | ចំណុចរំពុះ |
|---|---|---|---|
| $CH_3–CH_2–CH_2–CH_3$ | n–ប៊ុយតាន | 58g/mol | – 0.5ºC |
| $CH_3–CH_2–CHO$ | ប្រូប៉ាណាល់ | 58g/mol | 49ºC |
| $CH_3–CO–CH_3$ | អាសេតូន | 58g/mol | 56.1ºC |
| $CH_3–CH_2–CH_2–OH$ | ប្រូប៉ាន-1-អុល | 60g/mol | 97.2ºC |



RUPPDOC

# B. សេតូន

## ៤.លក្ខណៈរូបនៃសេតូន

- សេតូន ដែលមានម៉ាសម៉ូលេគុលតូចជាអង្គធាតុរាវ គ្មានពណ៌ មានក្លិនគួរជាទីគាប់ចិត្ត រលាយក្នុងទឹក ហើយភាពរលាយក្នុងទឹកថយចុះកាលណាចំនួនអាតូមកាបូនកើន។

| រូបមន្ត | ឈ្មោះ | ចំនុចរលាយ | ចំនុចរំពុះ | រលាយក្នុងទឹក |
|---|---|---|---|---|
| $CH_3COCH_3$ | អាសេតូន | –95ºC | 56.1ºC | មិនកំណត់ |
| $CH_3COCH_2CH_3$ | ប៊ុយតាណូន | –86ºC | 80ºC | រលាយខ្លាំង |
| $CH_3COCH_2CH_2CH_3$ | ប៉ង់តាន-2-អូន | –78ºC | 102ºC | រលាយ |
| $CH_3CH_2COCH_2CH_3$ | ប៉ង់តាន-3-អូន | –39ºC | 102ºC | រលាយ |
| $C_6H_5COCH_3$ | អាសេតូផេណូន | 21ºC | 202ºC | មិនរលាយ |
| $C_6H_5COC_6H_5$ | បង់សូផេណូន | 48ºC | 306ºC | មិនរលាយ |

RUPPDOC

# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.១ ប្រតិកម្មអ៊ីដ្រូសែនកម្ម (ប្រតិកម្មរេដុកម្ម)

- សេតូនមានប្រតិកម្មបូកជាមួយអ៊ីដ្រូសែន $H_2$ ឱ្យផលជាអាល់កុលថ្នាក់ II

$$R_1\text{–}CO\text{–}R_2 + H_2 \xrightarrow{\text{Cu ឬ Pt}} R_1\text{–}CHOH\text{–}R_2$$

សេតូន — អាល់កុលថ្នាក់II

- ឧទាហរណ៍៖

$$CH_3\text{–}\overset{\overset{\displaystyle O}{\|}}{C}\text{–}CH_3 + H_2 \xrightarrow{Cu}$$



RUPPDOC

# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.២ ប្រតិកម្មអ៊ីដ្រាតកម្ម

- សេតូនធ្វើប្រតិកម្មជាមួយទឹកឱ្យផលជាសេតូនអ៊ីដ្រាត

$$R_1\text{–}\overset{\overset{\displaystyle O}{\|}}{C}\text{–}R_2 + H_2O \rightarrow R_1\text{–}\underset{\underset{\displaystyle OH}{|}}{\overset{\overset{\displaystyle OH}{|}}{C}}\text{–}R_2$$

សេតូន — សេតូនអ៊ីដ្រាត

- ឧទាហរណ៍៖

$$CH_3\text{–}\overset{\overset{\displaystyle O}{\|}}{C}\text{–}CH_3 + H_2O \rightarrow$$

# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.៣ ប្រតិកម្មជាមួយ 2,4-DNPH

- 2,4-DNPH គេប្រើសម្រាប់អត្តសញ្ញាណកម្មបង្គុំកាបូនីល ពេលគេបន្តក់ចូលប៉ះជាមួយសូលុយស្យុងអាល់ដេអ៊ីត ឬ សេតូន ឱ្យកករពណ៌លឿងចាស់។



អាល់ដេអ៊ីត ឬ សេតូន | 2,4–ឌីនីត្រូផេនីលអ៊ីដ្រាស៊ីន | 2,4–ឌីនីត្រូផេនីលអ៊ីដ្រាសូន

កករពណ៌លឿងចាស់



# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.៤ អុកស៊ីតកម្មដោយបង្ខំ

- សេតូនរងអុកស៊ីតកម្មតាមបង្ខំផ្តាច់ខ្សែកាបូននៅពេលដែលវាជួបជាមួយអុកស៊ីតករ $K_2Cr_2O_7$ ឬ $KMnO_4$ ក្នុងមជ្ឈដ្ឋានអាស៊ីត $H_2SO_4$ ដោយមានការផុតកម្តៅ គេទទួលបានល្បាយអាស៊ីត។

$$R_1–CH_2–CO–CH_2–R_2 \xrightarrow{[O]} \begin{cases} R_1-CH_2-COOH + R_2-COOH \\ R_2-CH_2-COOH + R_1-COOH \end{cases}$$

សេតូន | ល្បាយអាស៊ីត

- ឧទាហរណ៍៖

$$CH_3–CO–CH_3 + [O] \rightarrow$$

RUPPDOC

# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.៥ ប្រតិកម្មជាមួយអាល់កុល

- សេតូនមានប្រតិកម្មជាមួយអាល់កុល បង្កើតបានទម្រង់អេមីសេតាល់។ ទម្រង់អេមីសេតាល់ជាទម្រង់មួយដែលមានក្រុម (–OH ) និងក្រុម (–OR) ជួសនៅលើអាតូមកាបូនតែមួយ។




- ឧទាហរណ៍៖





RUPPDOC

# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.៥ ប្រតិកម្មជាមួយអាល់កុល

- សេតូនមានប្រតិកម្មជាមួយអាល់កុលដោយមានបន្ថែមឧស្ម័នអ៊ីដ្រូសែនក្លរួ បង្កើតបាន ទម្រង់ សេតាល់។ ទម្រង់អាសេតាល់ ជាទម្រង់មួយដែលមានក្រុម(–OR)ពីរជួសនៅលើអាតូមកាបូនតែមួយ។




- ឧទាហរណ៍៖



# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.៦ ប្រតិកម្មជាមួយស្រឡាយអាម៉ូញ៉ាក់




| ស្រឡាយអាម៉ូញ៉ាក់ $H_2N–Z$ | ផលិតផលទទួលបាន |
|---|---|
| $H_2N–H$ អាម៉ូញ៉ាក់ | អ៊ីមីន |
| $H_2N–R$ អាមីនថ្នាក់I | អ៊ីមីន |
| $H_2N–OH$ អ៊ីដ្រុកស៊ីលឡាមីន | អុកស៊ីម |
| $H_2N–NH_2$ អ៊ីដ្រាស៊ីន | អ៊ីដ្រាសូន |
| $H_2N–NH–C_6H_5$ ផេនីលអ៊ីដ្រាស៊ីន | ផេនីអ៊ីដ្រាសូន |
| $H_2N–NH–CO–NH_2$ សេមីកាបាស៊ីត | សេមីកាបាសូន |



# B. សេតូន

## ៥.លក្ខណៈគីមីនៃសេតូន

### ៥.៧ ប្រតិកម្មជាមួយស្រឡាយអាម៉ូញ៉ាក់( អាមីនថ្នាក់II )

- សេតូនមានប្រតិកម្មជាមួយ អាមីនថ្នាក់ទីII ផលិតផលជា អេណាមីន (Enamine)។ អេណាមីន ជាសមាសធាតុមិនទាន់ឆ្អែត ដែលកើតឡើងនៅពេលដែលអាល់ដេអ៊ីត ឬ សេតូន មានប្រតិកម្មជាមួយអាមីនថ្នាក់ទីII។ ផលិតផលមានទម្រង់ជាអាល់សែន និងអាមីន។




- ឧទាហរណ៍៖ប្រតិកម្មរវាង ប៊ុយតាណូនជាមួយឌីមេទីលឡាមីនៈ



RUPPDOC

# B. សេតូន

## ៥.លក្ខណៈគីមីនៃអាល់ដេអ៊ីត

### ៥.៨ ប្រតិកម្មជាមួយអ៊ីដ្រូសែនស្យានួ

- អ៊ីដ្រូសែនស្យានួ មានប្រតិកម្មទៅលើបង្គុំកាបូនីល របស់អាល់ដេអ៊ីត ឬសេតូន ផលិតផលទទួលបានជា ស្យាណូអ៊ីឌ្រីន (Cyanohydrin)។




- ឧទាហរណ៍៖ប្រតិកម្មរវាង អាសេតូន ជាមួយ អ៊ីដ្រូសែនស្យានួ:





RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.១ ប្រតិកម្មអុកស៊ីតកម្ម ឬដេស៊ីដ្រូសែនកម្មអាល់កុលថ្នាក់II

$$R_1–CHOH–R_2 \xrightarrow{[O]} R_1–CO–R_2$$

អាល់កុលថ្នាក់I សេតូន

- ឧទាហរណ៍៖ អុកស៊ីតកម្មប្រូប៉ាន–2–អុលដោយសូលុយស្យុងប៉ូតាស្យូមឌីក្រូម៉ាត($K_2Cr_2O_7$) ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច$H_2SO_4$

$$Cr_2O_7^{2-} + 14H^+ + 6e^- \rightarrow 2Cr^{3+} + 7H_2O$$
$$CH_3–CHOH–CH_3 \rightarrow CH_3–CO–CH_3 + 2H^+ + 2e^- \quad (\times 3)$$
$$3CH_3–CHOH–CH_3 + Cr_2O_7^{2-} + 8H^+ \rightarrow 3CH_3–CO–CH_3 + 2Cr^{3+} + 7H_2O$$

RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.១ ប្រតិកម្មអុកស៊ីតកម្ម ឬដេស៊ីដ្រូសែនកម្មអាល់កុលថ្នាក់II

- ឧទាហរណ៍៖ ប្រតិកម្មដេស៊ីដ្រូសែនកម្មប្រូប៉ាន–2–អុលទទួលបាន ប្រូប៉ាណូន

$$CH_3{-}CHOH{-}CH_3 \xrightarrow{Cu\ /\ 300^\circ C} CH_3{-}CO{-}CH_3 + H_2$$

ប្រូប៉ាន–2–អុល ... ប្រូប៉ាណូន



RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.២ ប្រតិកម្មអ៊ីដ្រាតកម្មអាល់ស៊ីន

- អាល់ស៊ីនរងអ៊ីដ្រាតកម្មជាសេតូនដោយវត្តមានអំបិលបារ៉ែតII នៅចំពោះមុខ $H_2SO_4$រាវ

$$R_1{-}C{\equiv}C{-}H + H_2O \xrightarrow{Hg^{2+}\ /\ H_2SO_4} R_1{-}CO{-}CH_3$$

អាល់ស៊ីន ... សេតូន

- ឧទាហរណ៍៖ អ៊ីដ្រាតកម្មប្រូពីន

$$CH_3{-}C{\equiv}CH + H_2O \xrightarrow{Hg^{2+}\ /\ H_2SO_4}$$

RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.៣ ប្រតិកម្មអូសូនកម្ម

- ប្រតិកម្មអូសូនកម្មអាល់សែនដែលមានទម្រង់ជាអាល់សែនមានក្រុម ២ ៣ ៤ ផលិតផលទទួលបានជាសេតូន។




- ឧទាហរណ៍៖

45

RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.៣ ប្រតិកម្មអូសូនកម្ម

- ប្រតិកម្មអូសូនកម្មអាល់សែនដែលមានទម្រង់ជាអាល់សែនមានក្រុម ២ ៣ ៤ ផលិតផលទទួលបានជាសេតូន។




- ឧទាហរណ៍៖

46

RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.៣ ប្រតិកម្មអូសូនកម្ម

- ប្រតិកម្មអូសូនកម្មអាល់សែនដែលមានទម្រង់ជាអាល់សែនមានក្រុម ២ ៣ ៤ ផលិតផលទទួលបានជាសេតូន។




- ឧទាហរណ៍៖



RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.៤ ប្រតិកម្មអាស៊ីលកម្មហ្វ្រីដេល–ក្រាហ្វ ( Friedel-Crafts )

- ប្រតិកម្មនេះសម្រាប់ទង្វើសេតូនអារ៉ូម៉ាទិច




- ឧទាហរណ៍៖



RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.៥ ប្រតិកម្មសំយោគសេតូនពីនីទ្រីល

- នីទ្រីល (R–CN) ជាមួយរ៉េអាទីបគ្រីញ៉ាឬសមាសធាតុសរីរាង្គលីចូម ដោយអ៊ីដ្រូលីស

$$R_1{-}C{\equiv}N + R_2{-}Mg{-}X \xrightarrow{H_3O^+} R_1{-}CO{-}R_2 + NH_4^+ + Mg^{2+} + X^-$$

នីទ្រីល  រ៉េអាទីបគ្រីញ៉ា  សេតូន

- ឧទាហរណ៍៖

$$CH_3{-}C{\equiv}N + CH_3{-}Mg{-}Cl \xrightarrow{H_3O^+} CH_3{-}CO{-}CH_3 + NH_4^+ + Mg^{2+} + Cl^-$$

អាសេតូនីទ្រីល  អាសេតូន



RUPPDOC

# B. សេតូន

## ៦. ទង្វើសេតូន

### ៦.៥ ប្រតិកម្មសំយោគសេតូនពីនីទ្រីល

- នីទ្រីល (R–CN) ជាមួយរ៉េអាទីបគ្រីញ៉ាឬសមាសធាតុសរីរាង្គលីចូម ដោយអ៊ីដ្រូលីស

$$R_1{-}C{\equiv}N + R_2{-}Li \xrightarrow{H_3O^+} R_1{-}CO{-}R_2 + NH_4^+ + Li^+$$

នីទ្រីល  សរីរាង្គលីចូម  សេតូន

- ឧទាហរណ៍៖

$$CH_3{-}C{\equiv}N + CH_3{-}Li \xrightarrow{H_3O^+} CH_3{-}CO{-}CH_3 + NH_4^+ + Li^+$$

មេទីលលីចូម  ប្រប៉ាណូន

# B. សេតូន

## ៧. បម្រើបម្រាស់









# លំហាត់គំរូ១

- ចូរហៅឈ្មោះសមាសធាតុខាងក្រោម៖

ក. $CH_3-CH_2-\underset{\displaystyle CH_3}{\underset{|}{CH}}-CHO$

ខ. $CH_3-CO-CH_2-CH_3$

គ. $CH_3-CH_2-\underset{\displaystyle CH_3}{\underset{|}{CH}}-\underset{\displaystyle CH_3}{\underset{|}{CH}}-CHO$

ឃ. $CH_3-\underset{\displaystyle Cl}{\underset{|}{CH}}-\underset{\displaystyle Cl}{\underset{|}{CH}}-\underset{\displaystyle Cl}{\underset{|}{CH}}-CHO$

ង. $CH_3-CO-\underset{\displaystyle CH_3}{\underset{|}{CH}}-\underset{\displaystyle CH_3}{\underset{|}{CH}}-\underset{\displaystyle CH_3}{\underset{|}{CH}}-CH_3$

ច. $CH_3-CO-CH_3$

ឆ. $CH_3-CH_2-CO-CH_2-CH_3$

ជ. $CH_3-CH_2-CH_2-\overset{\displaystyle CH_3}{\overset{|}{\underset{\displaystyle CH_2-CH_3}{\underset{|}{C}}}}-CH_2-CHO$

# លំហាត់គំរូ២

គេមានគូសារធាតុពីរដូចខាងក្រោមដែលដាក់ក្នុងដបគ្មានស្លាក។ ចូរអ្នករកវិធីធ្វើតេស្តរកអត្តសញ្ញាណ ដើម្បីឱ្យដឹងថាដបណាផ្ទុកសារធាតុអ្វី៖

ក. ប៉ង់តាន និងប្រូប៉ាណាល់

ខ. ប្រូប៉ាន-1-អុល និងប្រូប៉ាណាល់

គ. ប៉ង់តាន-3-អុល និងប៉ង់តាន-3-អូន



# ដំណោះស្រាយ

RUPPDOC

# លំហាត់គំរូ៣

ផលបូកម៉ាស់ម៉ូលរបស់អាល់ដេអ៊ីត និងសេតូន ដែលជាអ៊ីសូមែនឹងគ្នាមាន144g/mol។ តើសេតូននេះមានរូបមន្ត និងឈ្មោះដូចម្ដេច?



RUPPDOC

# ដំណោះស្រាយ

RUPPDOC

# លំហាត់គំរូ៤

គេធ្វើអ៊ីដ្រាតកម្ម ប៊ុយ-1-អែន ។

a. ចូរសរសេររូបមន្ត និងឈ្មោះអាល់កុលA ដែលទទួលបាន។

b. បើគេធ្វើអុកស៊ីតកម្មតាមសម្រួលនៃAគេទទួលបានសមាសធាតុសរីរាង្គB ។ ចូរឱ្យឈ្មោះ និងរូបមន្តនៃB។

c. ទិន្នផលនៃប្រតិកម្មអ៊ីដ្រាតកម្មគឺ90% ឯប្រតិកម្មអុកស៊ីតកម្មគឺ70%។ តើគេទទួលបានម៉ាសBប៉ុន្មានក្រាម បើគេប្រើ ប៊ុយ–1–អែន 0.5kg។



RUPPDOC

# ដំណោះស្រាយ

RUPPDOC

## ដំណោះស្រាយ



RUPPDOC

# ជំពូកទី៤

# អាស៊ីតកាបុកស៊ីលិច, អេស្ទែ ខ្លាញ់ និងប្រេង

RUPPDOC

# មេរៀនទី១

# អាស៊ីតកាបុកស៊ីលិច

2

RUPPDOC

## វត្ថុបំណង

### ក្នុងមេរៀននេះយើងនឹងអាច៖

- រៀបរាប់លក្ខណៈទូទៅនៃអាស៊ីតកាបុកស៊ីលិច
- សរសេររូបមន្ត និងហៅឈ្មោះអាស៊ីតកាបុកស៊ីលិច
- ពណ៌នាលក្ខណៈរូប និងលក្ខណៈគីមី និងសរសេរប្រតិកម្ម ដែលកើតមានចំពោះអាស៊ីតកាបុកស៊ីលិច
- ពណ៌នាពីទង្វើ និងសារសំខាន់នៃអាស៊ីតកាបុកស៊ីលិចមួយចំនួន

3

# ១. និយមន័យ

- អាស៊ីតកាបុកស៊ីលិចជាសមាសធាតុសរីរាង្គដែលមានបង្គុំកាបុកស៊ីលក្នុងម៉ូលេគុល។
- បង្គុំកាបុកស៊ីលជាបង្គុំដែលមានបង្គុំអ៊ីដ្រុកស៊ីល(OH) ភ្ជាប់ទៅនឹងកាបូននាទីនៃបង្គុំកាបូនីល $(-\overset{O}{\overset{\|}{C}}-)$ បង្គុំកាបុកស៊ីល $-\overset{O}{\overset{\|}{C}}-OH$ ឬ $-COOH$។
- ទម្រង់ទូទៅរបស់ម៉ូណូអាស៊ីតកាបុកស៊ីលិច $R-\overset{O}{\overset{\|}{C}}-OH$ ឬ RCOOH ដែល R អាចជាអ៊ីដ្រូសែន រ៉ាឌីកាល់អ៊ីដ្រូកាបួ ស៊ីគ្លិច ឬ ប្រហើរ។
- ឧទាហរណ៍៖


អាស៊ីតផរម៉ិច


អាស៊ីតអាសេទិច


អាស៊ីតបង់សូអ៊ិច



# ១. និយមន័យ

តារាង.៣.១.ស្រឡាយនៃអាស៊ីតកបុកស៊ីលិច

| ទម្រង់ | ឈ្មោះ |
|---|---|
|  | អាស៊ីលក្លរ |
|  | អានីឌ្រីតអាស៊ីត |
|  | អេស្ទែ |
| $R-C\equiv N$ | នីទ្រីល |
|  | អាមីត |

# ២.នាមវលី

## ២.១ ឈ្មោះងាយ






# ២.នាមវលី

## ២.១ ឈ្មោះងាយ

| ចំនួនអាតូមC | រូបមន្តស្ទើរលាត | ឈ្មោះ IUPAC | ឈ្មោះងាយ | ប្រភព |
|---|---|---|---|---|
